ភិក្ខុ ក្រួច-លួន ភិក្ខុ សុខ-សម្បត្តិ

# ជីវិតគ្រូ

-ចែកជាធម្មទាន-

ក្នុងឱកាសរំលាយសព លោកអាចារ្យ **ភៅ-ស៊ាង**
នៅវត្តគោកធ្លក ឃុំទ័ពសៀម ស្រុកជីក្រែង ខេត្តសៀមរាប

ពីថ្ងៃទី ១១-១២ ខែឧសភា ព.ស. ២៥០៦ / គ.ស. ១៩៦៣

ចំនួន ១.០០០ ក្បាល

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

ភិក្ខុ ក្រួច-លួន ភិក្ខុ សុខ-សម្បត្តិ

# ជីវីតគ្រូ

-ចែកជាធម្មទាន-

ក្នុងឱកាសរំលាយសព លោកអាចារ្យ **កៅ-ស៊ាង**
នៅវត្តគោកធ្លក ឃុំទ័ពសៀម ស្រុកជីក្រែង ខេត្តសៀមរាប

ពីថ្ងៃទី ១១-១២ ខែឧសភា ព.ស. ២៥០៦ / គ.ស. ១៩៦៣

ចំនួន ១.០០០ ក្បាល



លោកគ្រូអាចារ្យ ភោង-ស៊ាង

អនិច្ចធម្មពីថ្ងៃ ចន្ទ ១១ រោច ខែភទ្របទ ឆ្នាំខាល

នៅក្នុងបញ្ចស័ក ព.ស. ២៥០៥ ត្រូវនឹងថ្ងៃ២៤

កញ្ញា គ.ស. ១៩៦២ ដោយជម្ងឺបួសប្លើម ៗ

# បញ្ជីរាប់ចំនួនឈ្មោះឧបាសក.សិកា

ដែលមានសទ្ធាជ្រះថ្លាចេញថ្លៃបោះពុម្ពសៀវភៅជីវិតគ្រូចែកជា

ធម្មទាន ក្នុងឱកាសបុណ្យរំលាយសពនៃលោកអាចារ្យ កៅ.ស៊ាង

| លេខរៀង | គោត្តនាម.បកតិនាម ឬនាមប្តីប្រពន្ធ | ទីលំនៅ | ឃុំ | ស្រុក | ខេត្ត | ចំនួនទឹកលុយ |
|---|---|---|---|---|---|---|
| ១ | ឧបាសកប៉ែត.ទេព | ភូមិប្រាសាទ | កំពង់ក្តី | ជីក្រែង | សៀមរាប | ២០៛ |
| ២ | ឧបាសិកាយ៉េន.ហ៊ុន | " | " | — | — | ២០ |
| ៣ | — ហស.អ៊ុន | " | " | — | — | ២០ |
| ៤ | — ប៉ាត់.ទៀង | " | " | — | — | ២០ |
| ៥ | — ហ៊ី.ជឹម | " | " | — | — | ២០ |
| ៦ | — អ៊ុន.កែន | បឹងកាំង សង្កាត់លេខ៤ ភ្នំពេញ កណ្តាល | | | | ៥០០៛ |
| ៧ | លោកសម.សុខុម | លេខាធិការនៅមន្ទីរពេជសហករណ៍ ភ្នំពេញ ចេញថ្លៃ ១០ ក្បាល | | | | |
| ៨ | លោក ប៉ា.ហ៊ាន | លេខាធិការនៅមន្ទីរពេជសហករណ៍ ភ្នំពេញ ចេញថ្លៃបគ្រិប | | | | |
| ៩ | ព្រះគ្រូបុត្តិមកសី អ៊ូ.ចៅ វត្តលង្កា ភ្នំពេញ ចំនួន ២០០៛ | | | | | |

ទីធម៌មិត្តសប្បុរសឯទៀតជាច្រើន តែពុំបានចុះនាមនៅក្នុងទីនេះ ។

# ជីវិតគ្រូ

និពន្ធដោយ

## ភិក្ខុតិក្ខវីរិយោ គ្រួច-លួន និង ភិក្ខុ សុខ-សម្បត្តិ ,

## ឧទ្ទិសកុសល

ចំពោះវិបាកវិញ្ញាណក្ខន្ធនៃសព ឧបាសក កៅ-សាន ជាអតីតចៅអធិការ និងជាអាចារ្យសម្រាប់វត្តគោកដូក ឃុំទំពាសៀម ស្រុកជីក្រែង ខេត្តសៀមរាប ; អនិច្ចធម្មពីថ្ងៃ ១១ រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥០៦ ។

ធ្វើនៅវត្តឧណ្ណាលោម ថ្ងៃ ១៦ មេសា ២៥០៧ / ១៩៦៣

# បុព្វកថា

កំណើតនៃធម្មកថា « ជីវិតគ្រូ » នេះ កើតឡើងដោយការពិតគិតគោលទៅរក ៖

ក) ការរិះគេមធ្យោបាយគាំទ្រទិន្នកា និង ពុទ្ធិប្រភាពនៃពុទ្ធ-បរិស័ទក្នុងវង់ការគ្រប់គ្រងនៃព្រះពុទ្ធសាសនា ,

ខ) ឧបាយយកយោនសត្វា ( ជំនឿ ) នៃសិស្សគណរបស់សពនៃឧបាសកាចារ្យ កៅ.សាន ដែលបានគេបបញ្ញាឃ្លាតឆ្ងាយពីពាក់រប់រំពីលោកគ្រូមកជាយូរឆ្នាំហើយ ឲ្យងាកត្រឡប់មកបរបាស អង្គុលភក្ដប្រយោជន៍សំរាប់ជីវិតរៀងរាល់ខ្លួនវិញ ដោយធម្មកថា គឺជីវិតគ្រូនេះ ,

គ) ជៀសវាងពីការប្រវាទពីមណ្ឌលតក្កវិទ្យា និងវិទ្យាសាស្ត្រ ដែលថា មាតាបិតា គ្រូបាអាចារ្យមិនមានគុណ ,

ឃ) ការអប់រំបរិស័ទក្រោមមធ្យោបាយដឹកនាំតាមគន្លងព្រះពុទ្ធសាសនា ឲ្យបានយល់ដឹងដល់ខ្លឹមសារនៃព្រះពុទ្ធកាលណែនាំ ។

បុព្វហេតុទាំងនេះ នាំឲ្យខ្ញុំនៅស្ងៀមពុំបានក្នុងការពោតថ្ងៃធ្វើបុណ្យរំលាយសពលោកអាចារ្យ កៅ.សាន ក៏រៀបនាជាសៀវភៅនេះឡើង ដោយស្ម័គ្រចិត្តរួមជាមួយប្អូនមហា សុខ.សម្បត្តិ ( ហៅ តី ) ផង ។

លុះសរសេររួចហើយ ខ្ញុំក៏យកសំណៅនេះ ទៅសុំសេចក្ដីអនុគ្រោះពីព្រះតេជះគុណព្រះគ្រូញាណសំវរ ប៉ែន.សុខ វត្តឧណ្ណាលោម ដែលជាសាស្ត្រាចារ្យរបស់ខ្ញុំតាំងពីរបួ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត. ព្រះអង្គលោកក៏យកព្រះទ័យទុកដាក់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ដោយមេត្តាសោមនស្សរីករាយ ៗ

អវសាន, ដោយអំណាចនៃវិរិយភាពដ៏ថ្លៃថ្លា និងចេតនាជាកុសលរបស់ខ្ញុំ សូមឲ្យវិញ្ញាណក្ខន្ធនៃលោក ពៅ.សារិន ជាឪពុកធំ បានប្រកបដោយវិបុលសុខហូតដល់និព្វាន, សូមពួកពុទ្ធបរិស័ទបានសេចក្ដីសុខចំរើនគ្រប់ចំណង់ចង់ប្រាថ្នា ហើយសូមឲ្យមានសាមគ្គីធម៌រឹងប៉ឹងក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា សូមថ្វាយព្រះពរកុសលចំពោះអង្គសម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចឪ សូមឲ្យព្រះអង្គទ្រង់មានព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏ត្រជាក់ក្សេមក្សាន្តតរៀងទៅ ៗ

ភ្នំពេញ, ថ្ងៃទី ១២ មេសា ២៥០៧ / ១៩៦៣

ភិក្ខុតិក្ខវីរិយោ គ្រួច.ល្អួន (ឡេង)

ភិក្ខុ សុខ.សម្បត្តិ (ទី)

# ប្រវត្តិសង្ខេប

នៃ

## លោកគ្រូអាចារ្យ ទោវ-សាំង

លោកអាចារ្យកើតថ្ងៃ ៥ ១៥ ៦ ឆ្នាំឆ្លូវ នៅភូមិព្រៃពាំង ឃុំទ័ពសៀម ស្រុកជីក្រែង ខេត្តសៀមរាប ។ បិតានាម **ទោវ** មាតានាម **ម៉ៅ** កុមារ ទោវ• សាំងមានវ័យវឌ្ឍនាការចំរើនធំឡើង បានអាយុ១៨ឆ្នាំ បានលាមាតាបិតា ទៅនៅសិក្សាអក្សរសាស្ត្រ, ព្រះពុទ្ធសាសនានៅវត្តគោកធ្លក ឃុំទ័ពសៀម ស្រុកជីក្រែង ខេត្តសៀមរាប ក្នុងសំ-ណាក់លោកគ្រូចៅអធិការ **ទែព-ហ៊ឹម** ។ លុះសិក្សាអក្សរលេខនព្វន្ត បានចេះដឹងល្មមសមគួរហើយ ដល់អាយុគម្រប់២០ យុវជន ទោវ•សាំង ក៏ចូលទៅប្រណិបតន៍លាមាតាបិតានិងញាតិសន្តាន ទៅសូមផ្នួសបួសជាសាមណេរបានមួយវស្សា ។ លុះដល់អាយុគម្រប់ ២១ ឆ្នាំ ក៏ចូលសុំបព្វជ្ជាឧបសម្បទា ជាភិក្ខុភាពក្នុងសំណាក់លោកគ្រូឧបជ្ឈាយ៍ នាម **ស៊ឹម** អនុគណស្រុកជីក្រែង ក្នុងពុទ្ធសីមា វត្តគោកធ្លកដដែល ។

ក្នុងរវាង ៥ វស្សា ភិក្ខុ ទោវ•សាំង បានសិក្សារៀនសូត្រធម៌វិន័យព្រះពុទ្ធសាសនាចេះដឹងគួរសម មានសេចក្ដីក្លាហានអង់អាចល្មមជាទី

ពឹងផ្អែកកិច្ចសាមណេរបាន ក៏លោកគ្រូចៅអធិការ រឹកចៈ-ហ៊ឹម បាន តែងតាំងឲ្យធ្វើជាគ្រូសូត្រស្តាំ ។ លោកគ្រូ គៅ-សារិន មានក្តីប្រតិពល ក្នុងធម៌អាថ៌សាស្ត្របាលី មានកេរ្តិ៍ឈ្មោះល្បីល្បាញ ដោយបាន បំពេញកិច្ចវត្តផ្សេងៗ តាមធម្មវិន័យព្រះពុទ្ធសាសនា មានឧបជ្ឈាយ វត្តជាដើម អាយុជាតម្រប់ ២៧ ឆ្នាំ លោកបានឡើងឋានៈជាចៅអធិការ វត្តគោកធ្លក ។ នៅក្នុងរយកាលនៃដំណែងនេះ លោកបានប្រឹង ប្រែងបណ្តុះបណ្តាលពង្រីកព្រះពុទ្ធសាសនា ដោយសម័យនោះ ស្ថិត នៅក្នុងកណ្តាប់ដៃនៃអាណានិគមបារាំងសែសរឹតត្បិតខ្លាំងពេក ការសិក្សា របស់លោក និង សកម្មភាពគ្រប់យ៉ាង ក៏បានបំពេញបន្តរតាមកាល សម័យរបស់លោកដែរ ។ លុះដល់ជន្មាយុជាតម្រប់ ៣៣ លោកក៏ លាចាកសិក្ខាបទទៅកាន់គ្រហាវាស ហើយលើកលោកភិក្ខុ អ៊ុំ-ខៀច (អាចារ្យសំរាប់វត្តសព្វថ្ងៃ) ឲ្យកាន់ដំណែងជាចៅអធិការជំនួស អាយុ ៣៦ ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍នឹងនាង ឡេង-ហួត នៅភូមិ ទំពាសៀម ។ ដល់ឆ្នាំខាលក៏រើផ្ទះសម្បែងមកនៅភូមិថ្មល់ ខាងជើង វត្តគោកធ្លក មានបុត្រតែមួយគត់ (ធ្វើគ្រូបង្រៀនសព្វថ្ងៃ), ប្រកប អាជីវកម្មជាកសិករ ។ ក្នុងការដឹកនាំព្រះពុទ្ធសាសនា វត្តគោកធ្លក ពុំមាននរណាដែលមានសមត្ថភាពអង់អាច ដើម្បីជាជំហរសាសនាខាង

ការចាកចេញនៃឧបាសក-ឧបាសិកាផ្ទាល់នោះ ក៏បានលើកលោកគ្រូបណ្ឌិត កៅ-សាំង ជាអាចារ្យសំរាប់វត្តគោកធ្លក ។

ក្នុងឋានៈជាអាចារ្យវត្តនេះ លោកគ្រូអាចារ្យ កៅ-សាំង ជាមួយនឹងលោកគ្រូចៅអធិការដែលឡើងកាន់ការវត្តជាបន្តមក តាំងពីគ្រូ អ៊ូ-កេង, លោកគ្រូសូត្រ **គង់-ឈួន**, លោកគ្រូ ប្រែង-ញ៉ក់, លោកគ្រូ **ខង-នុត**, លោកគ្រូ **សួរ-ពុត** ហៅ **ទៀប**, និងលោកគ្រូ **មាឃ-នល់** សព្វថ្ងៃនេះ លោកបានប្រឹងប្រែងដឹកនាំពុទ្ធបរិស័ទឲ្យចេះដឹងព្រះពុទ្ធសាសនាយ៉ាងក្រៃលែង តាមកាលៈទេសៈ និងបានជាជំហរសន្តិភាពដ៏រឹងប៉ឹងក្នុងទីវត្តគោកធ្លក ឃុំចំពាមសៀម ស្រុកជីក្រែង ខេត្តសៀមរាប លុះដល់អាយុ ៦២ ឆ្នាំ លោកគ្រូក៏ទទួលអនិច្ចកម្មដោយជរាពាធ នៅថ្ងៃចន្ទ ១១ កើតខែកត្តិក ឆ្នាំខាលក្នុងទោស័ក ព.ស. ២៥០៥ វេលាម៉ោង ៤ ព្រឹក ប្រកបដោយ សុគតិ ដ៏ប្រពៃ ។

# ឧទ្ទិសកថា

នាងខ្ញុំនាម **ឡេង-ហួត** ជាភរិយា និងបុត្រមួយរូប ព្រមទាំងញាតិមិត្រ និង សិស្សគណរបស់សព មានសេចក្ដីទុក្ខក្នុងចិត្តនិងអាល័យសោកស្ដាយជាខ្លាំង ចំពោះដំណើរឃ្លាតនិរាសបែកចេញពីផ្ទះសំបែងនៃយើងខ្ញុំ ដែលសពបានធ្វើកាលពីថ្ងៃ ១១ រោចខែភទ្របទ ហូតមកដល់ពេលនេះ ។ យើងខ្ញុំគ្រប់រូប គ្មានទេយ្យវត្ថុដ៏ប្រសើរល្មមនឹងផ្ញើតាមជូនក្រៅពីកុសលនេះទេ ។

ឱ ភស្ដា! លោកឪពុក! គេជគុណ! យើងខ្ញុំសូមរំលឹកជាថ្មីទៀត! ទោះបីលោកបានកពបដិសន្ធិ នៅទីណាកន្លែងណា ក៏សូមអញ្ជើញញាកមុខមករកយើងខ្ញុំ ជាប្រពន្ធកូននិងសិស្សគណព្រមទាំងញាតិមិត្រ ដែលកំពុងសំរិតសម្រាំងចេតនា នឹងទេយ្យវត្ថុដ៏ប្រសើរ ដែលមានព្រះសង្ឃជាស្រែបុណ្យ មានព្រះពុទ្ធបដិមាករជាប្រធាននេះ និងលើកជូនធម្មបណ្ណាការ សូមមេត្តាទទួលយកដោយទឹកសន្ដានចិត្ត ទឹកគិតថាជារបស់ខ្លួន ទុកដូចជាមហាសម្បត្តិដ៏ត្រជាក់ ដែលគេបានដោយកម្លាំងខ្លួនសុទ្ធ សាធុ:! ។

ប៉ុន្តែ បើដំណឹងនេះទៅពុំដល់ទេ យើងខ្ញុំសូមបួងសួងអស់ពពួកទេ

ទេវតា អាកាសទេវតា រុក្ខទេវតាទាំងទសទិស សូមមេត្តាអាណិត
ទៅប្រាប់ដំណឹងដែលផង ថាប្រពន្ធ កូន ចៅ សិស្សគណនិងសាច់សា-
លោហិតព្រៀងលាននៅឯអាយ មានក្តីអាល័យបានរៀបចំចាត់ចែង
ទេយ្យធម៌ ឧទ្ទិសជូនមក សូមមេត្តាទទួលយកដោយសេចក្តីសោមនស្ស
និងសេចក្តីសង្គ្រោះចំពោះញាតិដែលនៅសល់ឯអាយ ។

យទិ ហីនេ គតោ ហិនេ កាយទុច្ចរិតេន វា

ឥមិនា បុញ្ញតេជេន តម្ហា ហិនា បមុច្ចតុ ៕

បើស្វាមី / ឪពុក / គេជគុណ / ក្តាំងក្តាត់វិបាកវិញ្ញាណទៅ
នៅក្នុងភូមិវិបត្តិថោកទាប ដោយអនុភាពនៃកត្តាចេតនាជាកុសល និង
ទេយ្យធម៌ដ៏បរិសុទ្ធរបស់យើងខ្ញុំនេះ ទៅគេចកន្ត្រាក់ឆក់យោនវិបាក
វិញ្ញាណបដិសន្ធិរបស់លោកឲ្យរួចផុតរបូតពីទីថោកទាបនោះ ហើយ
ជំក្លល់លើទេវវិមានដ៏រុងរឿង មានមនុស្សវិមាន និងទេវវិមានជាដើម,

យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ

ឥមិនា បុញ្ញតេជេន ភិយ្យោ ភិយ្យោ បវឌ្ឍតុ ៕

បើវិបាកវិញ្ញាណរបស់លោក តែងគម្រង់ទៅកាន់ទេវភូមិជាទីក
ពយដ៏វិចិត្រដោយរតនៈហើយ . សូមតេជនៃបុណ្យនេះ ទៅទំនុកបំរុង

ផ្ទុងផ្តើមលោក ឲ្យរឹងរឹតតែប្រសើរវិសេសលើសលុបជាងមុនទៅទៀត បុះ ៗ

កាលណាបានទទួលទេយ្យធម៌របស់យើងខ្ញុំនេះហើយ សូមមេត្តាគយគន់រំពៃមើលថែរក្សាយើងខ្ញុំជាប្រពន្ធកូនទៅ និងសិស្សគណសាច់សារលោហិត ឲ្យបានជួបប្រទះតែនឹងសេចក្តីសុខចំរើនហូតដល់និព្វាន កុំបីឃ្លៀងឃ្លាតឡើយហោង ៗ

ប្រពន្ធកូន និងសិស្ស

សូមគោរពល់វេលា ! !

# គតិទី ១

គ្រូអាចារ្យ ជាអ្នកបង្ហាញផ្លូវ ។

មង្គលត្ថទីបនី

អ្នកដើរមុខបេះបន់ចោយ អ្នកដើរក្រោយបេះផ្លែកពុន

បុរាណសុភាសិត

សន្តានថ្ងៃ វិនយល្អ ; កាសិកខ្ញុំ

នែ ! ការបង្ហាញអត្ថដ៏ជ្រាលជ្រៅ តាមដើងគម្ពីរព្រះពុទ្ធសាសនា សុទ្ធសាធ យើងទុកជាកំការកើបលើមតិអ្នកប្រាជ្ញទាំងពួង វិនិច្ឆ័យវែកញែក ដោយល្អិតល្អន់ទៅចុះ !! ជីវិតគ្រូនេះ ខ្ញុំសូមនិយាយតាមបំណាំ ការសង្គ្រោះទៅលើសិស្សគណ ការគ្រួតត្រារបស់លោកគ្រូពីតៗ. តាមដែលខ្ញុំបេះចាំមក ទុកជាខ្នាត មើលមានសំកប់មិត្រគ្រូមុខខ្ញុំខ្លួនទៅ ។

មែនពិត របស់អ្វីមួយដែលជារបស់ពិត កាលបើអ្នកផងកំណត់ ទុកថាជាការធម្មតា. ក៏នៅតែរង់គុណតាប់ប្រសើរថ្លៃថ្នូរដដែល មិនអាចប្រែប្រួលទៅតាមបំណាច់នរណាបានឡើយ ៖ ម៉ែឪ កាលមិនទាន់ទទួលនាទីជាម៉ែឪ ក៏ជាកូនរបស់លោក ហើយអាចសិក្សារៀនម៉ែឪ ដើម្បីឡើងកាន់តំណែងជាម៉ែឪជាលំដាប់តៗគ្នា ឯលោកគ្រូ

ពល់រូប គ្រប់សុញ្ញាតិ នាំបានកណ្តាលនេះ កាលដែលនៅពីកុមារ ក៏ត្រូវតែត្រេះត្រដរប្រឹងសាងសន្សំវិជ្ជា គំនិតមារយាទត្រឹមត្រូវស្មោះ បំពោះ ដើម្បីកម្រង់ជីវិតនឹងឋានៈខ្លួនជាគ្រូរបស់កុមារ ដូចជាលោកគ្រូជាន់មុនដែរ ។ ប៉ុន្តែ លោកគ្រូគំណតគ្នា ជាន់ជួរគ្នាជាបន្តនោះ គង់មានការប្រែប្រួលរបបអប់រំកុមារ របៀបបង្រៀន ហ្វឹកហ្វឺនកុមារ តទៅ តាមជំនាន់កាលសម័យដែលបានកម្រៃ ឲ្យកាន់តែប្រសើរតាមសភាពខ្លួនផងដែរ ។

ជីវិតគ្រូ គឺជាជីវិតមួយ មានភាពត្រឡប់ត្រឡាយអណ្តែតខ្ពស់ជាជាងជីវិតណាៗទាំងអស់ ដូចជាជីវិតម៉ែឪដែរ ។

តែលោកគ្រូ, តាមមតិព្រះពុទ្ធជាអម្ចាស់នៃសត្វត្រៃភព, បានបែងចែកជាទី ២ បន្ទាប់ពីជីវិតម៉ែឪ តាមជើងគម្ពីរលោកហៅថា «ទុតិយាចារ្យ របស់សិស្សគណ» គឺជាអ្នកចាប់ដៃកដៃសិស្ស បង្វឹនសិស្សបន្តពីដៃម៉ែឪ បណ្តើរទៅតាមផ្លូវឧត្តមវិជ្ជា ។

ដើមឡើយ លោកគ្រូ កាលនៅពីកុមារ លោកគ្រូខំសង្វាតផុះទាត់ស្មារតីដោយការសិក្សាចំណេះវិជ្ជាគ្រប់យ៉ាង ពីសំណាក់លោកគ្រូរបស់ខ្លួន បន្ទាប់មក ការសិក្សានេះកម្រៃជីវិត ឋានថ្នាក់របស់លោកឲ្យមានគុណសម្បត្តិ ទីនបរិយាសម្បត្តិខ្ពង់ខ្ពស់ថ្លៃថ្នូរ តាមវិជ្ជាសម្បត្តិ

ដែលលោកបានរៀន បានអប់រំខ្លួនដែរ ។

បើញែកតាមប្រភពបច្ចេកទេស ដែលជាសាខានៃសង្គមវិជ្ជា, នៅក្នុងសង្គមនីមួយ ៗ, មានគ្រូពេទ្យ, គ្រូខាងជាងដែក. ឈើ. ស៊ីម៉ងត៍. ថ្ម, គ្រូអក្សរសាស្ត្រ, គ្រូបង្រៀនខាងធម៌វិន័យព្រះពុទ្ធសាសនា, គ្រូទាយ គ្រូស្តោះព្រួស គ្រូអាក្សឈ្មជំងួ ; គ្រូខាងវិជ្ជាចំបាំង គ្រូប្រដាល់ កីឡាជាដើម ៗ តែបណ្ដាគ្រូទាំងនោះ គ្រូដែលមានគុណតាមប្រសើរជាងគេ គឺគ្រូបង្រៀនអក្សរក្បួនច្បាប់ធម៌អាថ៌ សាស្ត្រាបាលីព្រះពុទ្ធសាសនានេះឯង ព្រោះជាអ្នកបើកភ្នែកចិត្ត គ្រាបៀកចិត្តឲ្យសិស្សបន្ទាប់ពីមាតាបិតាមក ៗ ជាពិសេសគ្រូនេះ មានការបង្ហាត់វិជ្ជាឲ្យសិស្សចេះទាំងទស្សនវិជ្ជាខ្លះ ៗ ដូចជាពន្យល់ថា ជនដ៏ពួកនេះជាជនពាល ពួកនេះជាបណ្ឌិត ៗ ពាលមានលក្ខណៈកក្រើកយ៉ាងនេះ យ៉ាងនោះ មានសំដីផ្អែមល្ហែមតែជាប់ដោយពិសពុលផង ។ ពួកបណ្ឌិតជាមនុស្សស្លូតត្រង់ក្លាហានអង់អាចមានព្យាយាមតំណរុង មានក្តីសុភាពក្នុងកុសលផ្សេង ៗ ។ ឯគ្រូក្រៅនេះ ជាអ្នកសម្រេចឧបនិស្ស័យដើមរបស់សិស្ស បើណាស្របពួកខាងជាងក៏បង្ខំឲ្យទៅខាងជាងទៅ, ណាចូលចិត្តខាងពេទ្យក៏បង្ខំឲ្យទៅខាងពេទ្យទៅ ។

អ្នកដំណើរដើរផ្លូវឆ្ងាយ មានមគ្គុទ្ទេសក៍ជាអ្នកនាំផ្លូវ បង្អួលបង្ហាញប្រាប់ថា: ផ្លូវនេះទៅចំស្រុកនេះ ភូមិនេះ ផ្លូវនោះទៅត្រង់ខេត្តនោះ ប្រទេសនោះ ព្រៃនោះ ទើបមិនវង្វេង អាចដើរទៅដល់គោលដៅរបស់ខ្លួនបាន ។ អ្នកជិះយន្តហោះ រថភ្លើងឬរថយន្ត មានអ្នកកាន់ចង្កូត ( ឡៃកុង ) ជាអ្នកបើកបរកាច់ចង្កូតញាក់ដម្រង់ផ្លូវ ។ ហ្វូងសត្វ មានបាឬមេ ដែលគេនិយមហៅថាមេខ្យល់ សម្រាប់ដើរមុខនាំហ្វូងសត្វទាំងអស់ដើររកស៊ី ។ មនុស្សប្រាថ្នាសេចក្ដីសុខចំរើន ឬប្រាថ្នាចង់បានចំណេះវិជ្ជាការនានា មានគ្រូបា-អាចារ្យជាអ្នកចាប់ដៃបង្អួលបង្ហាញប្រាប់ផ្លូវថា: ផ្លូវនេះប្រកបដោយសុខគួរប្រព្រឹត្ត ផ្លូវនោះមានទុក្ខទោស គួរគិតលះបង់, និងបង្ហាត់បង្ហាញចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ ។ ពិតមែនហើយ បុរសស្ត្រីគ្រប់រូប មិនមែនកើតឡើងហើយ ចេះដឹង ឬ បានទៅជាអ្នកប្រាជ្ញដោយត្រឹមតែម៉ែឪ បង្កើតឲ្យមានរូបកងប៉ុណ្ណោះទេ គឺឲ្យតែប៉ុចពន្លកកើតមានរូបកងហើយ ត្រូវតែសន្សំពូនចំណេះវិជ្ជា ដោយមានគ្រូជាអ្នកដឹកដៃនាំមុខ ។ ព្រោះថាមនុស្សយើងបើគ្មានគ្រូជាមេដឹកនាំ ខ្លួនគ្មានប្រៀនប្រដៅបង្ហាញផ្លូវល្អអាក្រក់, បង្រៀនចំណេះវិជ្ជាផ្លូវលោក - ធម៌ បើទុកជាចេះដឹងដោយខ្លួនឯង ក៏គង់កន្តប្រឡំ យល់ខុសថាជាត្រូវ យល់ត្រូវថាជាខុស

ស្ទាក់ស្ទើរក្នុងចិត្ត រកផ្លូវត្រឹមត្រូវពិតប្រាកដមិនឃើញ ប្រៀបដូចជាបុគ្គលដើរវង្វេងក្នុងព្រៃ ដែលគ្មានអ្នកណាបង្ហាញផ្លូវ រមែងពារទៅខាងនេះបន្តិច ខាងនោះបន្តិច រកផ្លូវចេញមិនឃើញ ឬប្រៀបដូចជាមនុស្សខ្វាក់ គ្មានគេដឹកដៃ តែងដើរចូលព្រៃ ចូលគម្ពោតដូច្នោះ ។ សមដូចបុរាណថា

« ឪបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយតន្ទង ពោះទីង់ឆ្ពោះទៅស្រុកតូចកំផង សឹងដូចបំណង នៃចិត្តចិន្តា ។ តែងចេះឯង ដូចអ្នកវង្វេង កណ្ដាលអគ្គា ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា ឥតអ្នកដឹកដៃ ។ សូម្បីរកផ្លូវ ពុំដែលទងត្រូវ សឹងពានឯព្រៃ ហេតុវៀតចេះឯង ឥតអ្នកដឹកដៃ ចិត្តនោះសង្ស័យ ដូចផល់ពុំផល » ។ ពាក្យបុរាណប៉ុន្មានឃ្លាខាងលើនេះ សឲ្យឃើញថា មនុស្សពិតជាបានគ្រូនាំផ្លូវ ពិតជាមានការចេះដឹងមកពីគ្រូ ដោយឥតសង្ស័យឡើយ ។

ដូច្នេះសិស្សពិតជាគ្រូបា-អាចារ្យ ប្រសិទ្ធិចំណេះវិជ្ជាមន្តឲ្យ មិនមែនព្រះឥន្ទ្រព្រះព្រហ្មណ៍ទេវតាណា ដឹកដៃឬប្រទានមន្តអាគមឲ្យសិស្សទេ ឃើញតែចេះអំពីគ្រូដូចៗគ្នា ។ ចុះសព្វគ្រប់រូបមុននឹងមានសិស្ស ក៏មិនមានឈ្មោះថាគ្រូ ឬហៅថា « គ្រូ »

បានទេ លុះត្រាតែមានសិស្សហើយបង្រៀនសិស្ស ព្រោះ បង្រៀនតិចក្ដី ច្រើនក្ដី ឲ្យចេះដឹង ទើបបាននាមបញ្ញត្តិថា « គ្រូ » បុរាណថា " ប្រាប់ធម៌មួយមាត់ អក្សរមួយនៃ អ្នកនោះប្រពៃ ជាគ្រូបាធ្យាយ ។

គ្រូជានាមថ្មីជាសម្មតិនាម របស់លោកអ្នកដែលមានគុណធម៌ គួរជាទីស្រឡាញ់ គួរជាទីគាប់ចិត្ត គួរជាទីគោរព គួរជាទីសរសើរ របស់សិស្ស ទាំងសមគួរជាអ្នកពោលរំលឹកដាស់តឿនរឿយៗ ជាអ្នកអត់ធន់ក្នុងកិច្ចធ្ងន់ធ្ងររបស់សិស្សានុសិស្ស ជាអ្នកញាក់បំបែរសិស្សមិនឲ្យប្រកបការងារខុស ៗ ធម៌ប៉ុណ្ណោះជាដើម ជាធម៌ប្រក្រតី ជាធម៌សក្តិសិទ្ធិរបស់សិស្ស មានតម្លៃដ៏ធំធេង មានទម្ងន់ធ្ងន់ពន់ណាស់ផង មានន័យដូចគ្នា តែអ្នកផងច្រើនតែកំបាំងភ្នែក មើលមិនសូវឃើញថាមានគុណភាព មានតម្លៃត្រឹមនោះទេ គេច្រើនទុកដាក់ថាជារបស់ធម្មតាទៅវិញ, ហេតុដល់សម័យបច្ចុប្បន្ននេះ មានអ្នកខ្លះយល់ថាគ្រូគ្រាន់តែជាអ្នកស៊ីឈ្នួលប៉ុណ្ណោះក៏មាន តើ! របស់អ្វីមួយ ព្រោះជាមានឫទ្ធិអំណាចដ៏សក្តិសិទ្ធិ មានតម្លៃកាត់ថ្លៃមិនបានយ៉ាងណាក៏ដោយ បើគេពុំបានពិចារណាពិនិត្យពិស្ដារឲ្យច្បាស់លាស់ទេ របស់អស់នោះរមែងក្លាយទៅជារបស់ធម្មតាប្រក្រតីវិញ ហើយច្រើនតែកំបាំងភ្នែក

គេមើលពុំសូវឃើញទៀតផង តែយើងគប្បីចូលចិត្តថា ការដែលពិត បើអាក្រក់នៅតែអាក្រក់ ល្អនៅតែល្អ ឥតមានប្រែប្រួលសភាពពិត ទៅជាប្រការដទៃឡើយ ។

គ្រូកាលបើមានសិស្សហើយ តែងតែស្រឡាញ់ករុណាសិស្ស ចិញ្ចឹមបីបមថ្នាក់ថ្នមទំនុកបំរុងអប់រំបំប៉នសិស្ស ឲ្យសិស្សឲ្យពាសគ្នា បង្ហាត់បង្រៀនសិស្ស ដូចជាការបង្រៀនឲ្យមានសណ្តាប់ធ្នាប់ បង្រៀនឲ្យចេះសុជីវធម៌ សីលធម៌ ចំពោះព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យជាដើម និងបង្រៀនអក្សរ លំដាប់ច្បាប់ទំលាប់ផ្សេង ៗ ព្រមទាំងពន្យល់សិស្សឲ្យយល់ច្បាស់លាស់អំពីហេតុល្អ ហេតុអាក្រក់ ផ្លូវល្អ-អាក្រក់ , បង្វឹកសិស្សឲ្យចេះលះបង់ចោលអំពើអាក្រក់ណាមួយ ដូចជាការហាមមិនឲ្យប្រព្រឹត្តគន្លងអបាយមុខ(១) ជាដើម បង្ហាញផ្លូវត្រូវឲ្យចេះធ្វើ ចេះប្រព្រឹត្តប្រតិបត្តិសន្សំអំពើល្អ អំពើណាដែលជាប្រយោជន៍ដល់ខ្លួន និងដល់សាធារណជនទូទៅ ។ ទឹកសំរីដែលជាទឹកចិត្តផុសចេញមក ពីទឹកចិត្តដ៏ប្រកបដោយព្រហ្មវិហារធម៌របស់គ្រូ ស្រោចស្រពទៅលើ

(១) — អបាយមុខ ៦ យ៉ាង ការប្រកបរឿយ ៗ ក្នុងការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ១, ការត្រាច់ដើរលេងតាមច្រកល្ហកក្នុងវេលាយប់ខុសកាល១, ការដើរមើលល្បែងមហោស្រព១, ការលេងល្បែងភ្នាល់១, សេពគប់បាបមិត្រ១, ការទំអកទំរម្ងិលច្រអូស១ ។

សិស្សគ្រប់រូប ក្នុងពេលដែលលោកបង្រៀនប្រដៅបង្ហាត់បង្រៀននេះ ហាក់ដូចជាមុតច្បុះជ្រាបចូលដល់ថ្លើមប្រមាត់របស់សិស្ស ធ្វើឲ្យសិស្សភ្ញាក់គំនិតរលឹកស្មារតី ខំប្រឹងប្រែងព្យាយាមលះបង់សេចក្ដីងងឹតអន្ធការ ( ល្ងង់ខ្លៅ ) ចេញពីខ្លួន ប្រមូលសន្សំវេចខ្ចប់ខ្ញូវការចេះដឹង មានភាពសមរម្យប្រសើរឡើងជាលំដាប់ ៗ នេះជាការពិតណាស់ ឧបមាដូចជាឱសថដ៏សក្ដិសិទ្ធិ ដែលគ្រូពេទ្យស្រោចស្រព្យាប ឬ ចាក់បញ្ចូលទៅផ្សព្វផ្សាយក្នុងកាយរបស់អ្នកជម្ងឺដែលឈឺមិនដឹងខ្លួន ធ្វើឲ្យអ្នកជម្ងឺភ្ញាក់ដឹងខ្លួន ហើយខំប្រឹងលេបថ្នាំ ផឹកថ្នាំតទៅទៀត ដើម្បីកំចាត់រោគឲ្យជាដាច់ស្រឡះពីកាយខ្លួនដូច្នោះ ៗ ឯគ្រូខ្លួនលោក ដែលខំប្រឹងពេញទំហឹងអស់កម្លាំងកាយ កម្លាំងប្រាជ្ញា បង្រៀនសិស្ស ដោយពិធីផ្សេង ៗ ដើម្បីឲ្យសិស្សចាប់ចេះ ចាប់យល់ ក្រស្នាន យល់ត្រូវតាមមាគ៌ាដ៏ល្អ ពិតប្រាកដប្រាសចាកការភន្តច្រឡំ ខុសថាត្រូវ ត្រូវថាខុសនោះ ទុកដូចឱសថការីដ៏ចំណានមួយ ដែលបានខំរិះរកមធ្យោបាយលាយថ្នាំផ្សំថ្នាំឲ្យមានគុណភាពខ្លាំងពូកែ អាចចូលទៅកំចាត់រោគអ្នកជម្ងឺ ឲ្យជាយ៉ាងដាច់រហ័សដូច្នោះឯង ៗ

ដោយហេតុនេះ លោកគ្រូមាននាមមួយទៀតថាជាគ្រូពេទ្យរបស់សិស្ស សំដីទូន្មានរបស់លោកទុកដូចជាឱសថសម្រាប់កែរោគសិស្ស ៗ

រោគក្នុងទីនេះ សំដៅយកសេចក្ដីល្ងិតល្ងង់ទៅ ដែលតាមទ្រឹស្ដីពុទ្ធសាសនា លោកចាត់ទុកថាជារោគខាងក្នុង របស់មនុស្សជាតិ ។ រោគនេះ, កាលបើមិនប្រញាប់ប្រញាល់រកពេទ្យ គឺលោកគ្រូមកព្យាបាលឲ្យបានជាដាច់ហើសះទេ, រមែងតែឯតែញាំញី ធ្វើឲ្យមនុស្សវង្វេង ឈឺអន្ទើតអន្ទក់ហួតដល់វង្វេងមិនស្គាល់ម៉ែឪឯងក៏មានដែរ ព្រោះថា រោគ ឬ ជម្ងឺគឺការឈឺចាប់ដ៏កាចសាហាវ ដែលអាចបំផ្លាញផ្ដាច់ផ្ដិលជីវិតសត្វលោក ឲ្យដល់សេចក្ដីសាបសូន្យវិនាសអន្តរាយ ព្រាត់ប្រាសទ្រព្យសម្បត្តិ កូនប្រពន្ធ ដូចជារោគរបេងរីងរៃ ឃ្លង់ អុតធំ ។ល។ ពិសគ្រុនសន្និជាដើម ពេទ្យហ្ម ឬ គ្រូស្ដោះ អាចព្យាបាលជាសះស្បើយខ្លះ ដោយវិធីវាក់ថ្នាំខ្លះ ដោយឲ្យថ្នាំលេបផឹកខ្លះ ដោយការស្ដោះព្រួសដោយមន្តអាគមផ្សេងៗខ្លះ ។ ប៉ុន្តែចំណែកឯរោគ គឺសេចក្ដីល្ងង់ទៅ មិនស្គាល់ខុសត្រូវ មិនស្គាល់ល្អអាក្រក់ មិនស្គាល់ផ្លូវណាប្រព្រឹត្តទៅបានសុខចំរើន ផ្លូវណាប្រព្រឹត្តទៅបានទុក្ខបានទោស វិនាសអន្តរាយ បង់ខាតទ្រព្យសម្បត្តិវិញ, បើមិនមានគ្រូជាពេទ្យព្យាបាលឲ្យជាដាច់ស្រឡះទេ ហើយបណ្ដោយទុកឲ្យរោគនេះ ចាក់ឫសស៊ប់នៅក្នុងខ្លួនយើងបានមាំហើយ, ក្នុងលោកនេះនឹងរកពេទ្យពូកែចំណាននណាមកព្យាបាលឲ្យជា ដូចគ្រូបា អាចារ្យ

មិនមានឡើយ ។ មានតែគ្រូអាចារ្យទេ ដែលអាចលុញសូទ្យ ថ្នាំគុលិកាឲ្យសិស្សផឹក-លេប ហើយធ្វើឲ្យទៅជាអ្នកគ្មានរោគល្ងង់ទៀតបាន ។ ការព្យាបាលរោគសិស្សនេះ គ្រូត្រូវដាក់តំណមឲ្យសិស្សតមយ៉ាងតឹងរ៉ឹង ដូចជាឲ្យតមមិនឲ្យប្រព្រឹត្តអំពើអាក្រក់មានអបាយមុខ ៦ ជាដើម តមមិនឲ្យទំអក់ទំរន់ បណ្តែតបណ្តោយខ្ជិលរៀនសូត្រជាដើម ដាក់ថ្នាំឲ្យលេបផឹក ដូចជាការនិយាយប្រដៅទូន្មានឲ្យខំសិក្សារៀនសូត្រ ដោយពាញហេតុ.ផល នៃអំពើអាក្រក់ និងអំពើល្អ, សេចក្តីខ្ជិលច្រអូសនិងសេចក្តីស្វាហាប់ខ្មីឃ្មាត មកលាតត្រដាងបង្ហាញប្រាប់ឲ្យយល់ជាក់ច្បាស់ផង ។ល។ នេះជាឱសថរបស់គ្រូ ។

ការព្យាបាលរោគសិស្ស គឺការបង្ហាត់បង្រឹកសិស្ស ឲ្យចេះដឹងវិជ្ជាផ្សេង ៗ ប្រដៅពត់សិស្សឲ្យបានទៅជាមនុស្សប្រដៅឆាយ ជាមនុស្សល្អលុះតាមដំបូន្មានរបស់ខ្លួន នេះជាភារៈធ្ងន់ណាស់កម្រក្រៃ ក្រជាទីបំផុត (ក្រៅតែពីគ្រូបាអាចារ្យស្ទើរតែគ្មាននរណាធ្វើដូចបានឡើយ ) ។ គ្រូបាអាចារ្យ ត្រូវព្យាយាមធំបំផុត ដោយកាយ ដោយវាចា ដោយចិត្ត ដោយពិធីគ្រប់បែបយ៉ាង តាមដែលអាចធ្វើបាន ដើម្បីឲ្យសិស្សចេះដឹង ឲ្យសិស្សល្អ ។ គ្រូបាអាចារ្យមិនមែនត្រឹមតែគ្រូ ឬ ពេទ្យរបស់សិស្សប៉ុណ្ណោះទេ គឺជាគ្រូ ឬ ពេទ្យ

របស់ប្រជាពលរដ្ឋ របស់លោក ព្រោះប្រជាពលរដ្ឋគ្រប់ប្រទេស សុទ្ធសឹងតែមានគ្រូជាអ្នកដឹកនាំផ្លូវដូច ១ គ្នា ។

ហេតុនោះ គ្រូឈ្មោះថាជាអ្នកជួយជាតិ ធ្វើលោកឲ្យមានសន្តិ-ភាព មួយរូបយ៉ាងចំណាន ព្រោះការធ្វើសិស្សឲ្យយល់ច្បាស់នូវផ្លូវល្អ-អាក្រក់ ផ្លូវនាំឲ្យកើតទុក្ខ សុខ.ចំរើន និងផ្លូវវិលត់ទុក្ខ ព្រមទាំងធ្វើសិស្សឲ្យចេះចំណេះវិជ្ជា គ្រប់បែប គ្រប់ប្រភេទនេះ ហាក់ដូចជាធ្វើប្រទេសឲ្យមានជំហានលឿនទៅមុខ ឬ ធ្វើលោកឲ្យមានសន្តិភាពដូច្នោះឯង ។ ព្រោះសិស្សនៅមានសាកលលោកនេះ កាលបើបានស្គាល់ផ្លូវឲ្យកើតទុក្ខផ្លូវវិលត់ទុក្ខច្បាស់ពិតប្រាកដហើយ នឹងរកបង្កហេតុឲ្យពិភពលោករលាយខ្ទេចបង់ដូចម្ដេចកើត ? នេះជាធម៌ដ៏ប្រសើរក្រៃលែងណាស់ ។ ដោយអាស្រ័យហេតុនេះហើយបានជាលោកពោលថាគ្រូបាអាចារ្យ ជាបុព្វការីបុគ្គលមានគុណធ្ងន់ក្រៃណាស់ និង គណនាព្រាកប់ពុំបានឡើយ ។

ចំណែកសិស្សដែលបានទទួលឧបការៈ ពីគ្រូបាអាចារ្យ ដែលបានជួកកោណសំណាក់អាស្រ័យ ក្រេបជញ្ជក់យកចំណេះវិជ្ជា ហើយបានសុខសប្បាយត្រជាក់ត្រជុំក្សេមក្សាន្ត ចេះដឹងក្លាហានតាគពេកងនឹក គិតសេចក្ដីល្អធំទៅ បានឃើញច្បាស់នូវសុភមង្គល នៅក្នុងចិត្តនៃ

ខ្លួនហើយ គួរតែបង្អោនចិត្តទៅរកគ្រូ គោរពថ្វាយបង្គំនមស្ការគ្រូ ទុកដូចជាម៉ែឪ ទុកជាទេវតា ទុកជាព្រះរបស់ខ្លួន ។ ម្យ៉ាងទៀត ដោយអំណាចព្រហ្មវិហារធម៌របស់គ្រូ ដែលគ្រូបណ្តប់ទៅលើសិស្ស ពេលមានអាសន្ន មានទុក្ខធំ សិស្សគ្រាន់តែហៅ ឬ នឹកគិតក្នុងចិត្តថា ឱ! គុណគ្រូជួយប៉ុណ្ណោះ ក៏អាចរសាយទុក្ខខាកពីខ្លួនបានខ្លះដែរ ។ ហេតុនោះបានជា ពាក្យថាគ្រូនេះ ជាពាក្យមានគុណានុភាពធំណាស់ ហាក់ដូចជាឱសថទិព្វ ដែលអាចបន្សាបរោគឲ្យជាយ៉ាងឆាប់រហ័ស ។

នៅទីបំផុត ជីវិតគ្រូនឹងជីវិតសិស្ស មានការប្រាស្រ័យទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ជីវិតគ្រូក៏គឺជីវិតសិស្ស ជីវិតសិស្សក៏គឺជីវិតគ្រូ បើសិស្សបានទុក្ខគ្រូក៏កើតទុក្ខតាមសិស្ស គ្រូមិនត្រឹមតែជាគ្រូពេទ្យព្យាបាលរោគល្ងង់ខ្លៅប៉ុណ្ណោះទេ គ្រូជាគ្រូពេទ្យព្យាបាលរោគផ្សេង ៗ ទៀត ដូចជានៅពេលដែលសិស្សមានជម្ងឺឈឺមិនជាដោយរោគផ្សេង ៗ គ្រូចេញមុខធ្វើជាគ្រូពេទ្យ គ្រូស្ដោះ ដោយខ្លួនឯង ។ សិស្សកាលបើបានទទួលការថ្នាក់ថ្នមព្យាបាលពីគ្រូហើយ ទោះជាមានជម្ងឺប៉ុនណា ក៏អាចធូរស្រាលក្សាន្តតាករោគបានខ្លះ នេះចំជា « ឱសថ » មែន ៗ

ផ្ទុយពីនេះទៅវិញ បើអ្នកដឹកដៃ (គ្រូ) មានគុណវិបត្តិ៖ មានចំណេះល្បៀនឃ្លៀនឃ្លាតទៅឆ្ងង មិនឈ្លាសវៃ យល់ខុសជា

ត្រូវ យល់ត្រូវជាខុស ល្អជាអាក្រក់ អាក្រក់ជាល្អ គុណជាទោស ទោសជាគុណ, សិស្សគណក៏មានការល្ងាក់ល្ងើក ទ្រេតទ្រោតទ្រេម ទ្រោមតាមគ្រូនោះដែរ ព្រោះហេតុនោះហើយបានជា បុរាណបញ្ជាក់ថា: ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រចិត្តធានា ក្រវិជ្ជាចាស់ ឆ្ងាយឆ្ងាស លោកា ក្របានជាបា មេគេនាំឲ្យអាយ ។ ប៉ុន្តែបើអ្នកនាំផ្លូវល្អ ឈ្លាសវៃប្រតិពលប្រាកដប្រាជ្ញា យល់ច្បាស់នូវផ្លូវលោកផ្លូវធម៌ ប្រកបដោយគុណពោលគឺ នាយកធម៌ (១) សិស្សានុសិស្សនិងជនានុជន ក៏ល្អល្អើនមានសាមគ្គីធម៌ ឥតមានផុយមោសអ្វីឡើយ ។

ដោយហេតុនេះ នាទីដឹកនាំសិស្ស ជានាទីរបស់លោកគ្រូ ដែលជាអាចារ្យ ទី ២ របស់សិស្ស ។ គួរតែសិស្សគណជឿគោរព ប្រតិបត្តិស្តាប់បង្គាប់ចំពោះលោក ហើយគោរពយ៉ាងហ្មត់ចត់នូវគុណូបការរបស់លោក កុំប្រមាថមើលងាយដុតបាតដៃចាំងចទឹក, ទោះបីដេកក្តី ដើរក្តី ឈរក្តី អង្គុយក្តី គួរតែនឹកគិតពីចំពោះនឹងគុណគ្រូ ឲ្យដូចជាម៉ែឪរបស់ខ្លួនរាល់វេលា កុំបីភ្លេចខានឡើយ ។

---

១— នាយកធម៌ ៦: ១ ធម៌ៈ មានសទ្ធានចិត្តមាំងជឹង ប៉ះអត់ធ្មត់ច្រើន, ២— ជាគរយៈ មានការភ្ញាក់រលឹកចំពោះហេតុការណ៍ផងវៃរហ័សរហួន មិនស្ពឹក។ ៣— សីរីកោរៈ បែងរំលែកលាភសក្ការៈ របស់ក្តីរាប់អានដល់សិស្សស្មើល្អ, ៤— ទមៈ: មានឥន្ទ្រិយស្រគតស្រគំរីករាយល្អ, ៥— ឥក្ខនា: យល់ច្បាស់នូវហេតុ ដែលច្បាប់ទម្លាប់ស្រុក, ៦— ខន្តីៈ មានចិត្តរាំសរវៃប្រឹងប្រែងក្រៃលែងក្រោកឡើងការងារមុន ។

# គតិ ទី ២

## គ្រូជាកល្យាណមិត្តរបស់សិស្ស

ចាកពុទ្ធភាសិត

### គ្រូថែទាំសិស្ស

ម៉ែឪបង្កើតកូនមកហើយ មានភារៈចិញ្ចឹមថែរក្សាកូនឲ្យរស់នៅ ឲ្យបានសុខចំរើន ឲ្យបានទៅជាមនុស្សល្អ មនុស្សប្រសើរយ៉ាងណាមិញ ឯគ្រូគ្រប់ថ្នាក់គ្រប់ជាន់ ក៏យ៉ាងនោះដែរ កាលបើមានសិស្សហើយ ក៏មានភារៈត្រូវថែរក្សា ទំនុកបំរុង ផ្គុងផ្តើមសិស្ស ឲ្យសិស្សបានធូរស្រាលកក់ក្តៅដោយសារខ្លួន មិនមែនគ្រាន់តែបង្ហាត់បង្រៀនហើយ លែងពោលឲ្យដើរឬប្រព្រឹត្តស្មានគ្មានគោលដៅសោត អណ្តែតឥតបង្គោលជាបង្អែក ដូចជាសំណាក់ដែលអណ្តែតក្នុងទន្លេនោះទេ ។ គ្រូមានភារៈកិច្ចធ្ងន់ធ្ងរ ក្នុងការជ្រោមជ្រែងឧបត្ថម្ភសិស្ស ឲ្យបានជាឧត្តមសិស្ស ស្មើទន្ទឹមនឹងម៉ែឪរបស់សិស្សដែរ ។ បើយើងពិចារណាឲ្យវែងឆ្ងាយទៅទៀត ឃើញថាគ្រូលំបាកក្នុងកិច្ចនេះជាងនរណាទៅទៀត ព្រោះគ្រូមិនមែនការពារថែទាំសិស្សត្រឹមតែ ៤-៥នាក់ ប៉ុណ្ណោះទេ គ្រូមានកូនសិស្សយ៉ាងតិច ១០ ឬ ២០ នាក់ ជួនកាល

មានរហូតដល់ទៅ ៤០ នាក់ក៏មាន ម្ល៉ោះហើយការរៀនរៀបរយមនុស្ស ច្រើន តែងតែលំបាកចិត្ត លំបាកកាយយ៉ាងណាទៅ ? យើងអាចឆ្លើយថាលំបាកណាស់មិនអាចពណ៌នា ដូចជាអ្នកកាន់ចង្កូតរដ្ឋ ឬប្រមុខប្រទេសទីមួយ ៗ - លំបាកនឹងគ្រប់គ្រងប្រជាពលរដ្ឋ ឲ្យបានស្រុះស្រួលមូលសាមគ្គីគ្នា កុំឲ្យបែកបាក់គ្នាជាបក្សជាពួកជាក្រុម និងធ្វើឲ្យប្រទេសចំរុងចំរើនរុងរឿងយ៉ាងណា គ្រូក៏មានការលំបាកនឹងគ្រប់គ្រងថែរក្សាសង្គមសិស្ស មានទម្ងន់ធ្ងន់យ៉ាងនោះដែរ ។

អើ! ចិត្តគ្រូក៏ដូចជាចិត្តមាតាបិតាដែរ សុទ្ធតែមានព្រហ្មវិហារធម៌ គ្រូបណ្ដាប់ស្រោចស្របទៅលើសិស្សនឹងកូន ចង់ឲ្យសិស្សនឹងកូនមានជីវិតរស់នៅពិតៗ កាលបើសិស្សនឹងកូនមានជីវិតរស់ហើយ ចង់ឲ្យសិស្សនឹងកូនទៅជាមនុស្សល្អ, មនុស្សមានសុចរិយា, មនុស្សថ្លៃថ្នូរទាន់សម័យដូចគេ ៗ នេះជាការជាក់ប្រាកដណាស់ ដែលយើងពល់គ្នាជាសិស្សគួរតែគោរពលោកទុកដូចជាម៉ែឪ· ទុកជាព្រះអរហន្ត ហើយនមស្ការពល់វេលាកុំឲ្យខាន ។ សេចក្ដីដូចរៀបរាប់មកនេះ បុរាណក៏លោកបានបញ្ជាក់សរសើរអំពីចិត្តគ្រូ នឹង ម៉ែឪជាចិត្តតែមួយ ដូចស្លោកថា:

«ឱគ្រូបាធ្យាយ៍ អាចឲ្យពណ្ណកាយ មានរូបស្មើ ហើយឲ្យរុង

រៀន អស់បញ្ញើខ្លួនឲ្យ ស្មើព្រះជននី ជនកសោតហោង » ។ នេះបញ្ជាក់អំពីទឹកព្រះទ័យ ដ៏ប្រកបដោយមេត្តាធម៌ របស់គ្រូ ក្នុងការថែរក្សាទ្រោលបំភ្លឺសិស្ស ចង់ឲ្យមានស្មើក្សាន្តរៀន ស្មើនឹងទឹកចិត្តរបស់មាតាបិតាដែរ ។ មួយឃ្លាទៀតថា « គ្រូបាធ្យាយ៍ ប្រដូចនូវម្តាយ ផុតកឯងហោង អាចឲ្យក្តីច្បាប់ ប្រដៅធម៌ផង ដោយនូវគន្ធ ព្រះពុទ្ធតាំងឡាយ » ។ ឃ្លានេះទៀត ក៏សឲ្យឃើញថា គ្រូនឹងម៉ែឪរបស់សិស្ស មានចិត្តស្របគ្នាតែមួយ ចង់ឲ្យសិស្សល្អ ជាពិសេសចង់ឲ្យសិស្សប្រព្រឹត្តតាមមាគ៌ានៃពុទ្ធសាសនា ដែលមានព្រះពុទ្ធជាមេសាស្តា ។

ឯធម៌ថែរក្សាសិស្ស យើងអាចឃើញជាក់ច្បាស់នឹងភ្នែកខ្លួនមកហើយ គឺសូម្បីតែនៅពេលដែលយើងមកសំណាក់ចាក់ចុះជ្រកកោនជាមួយនឹងលោក សូមធ្វើជាសិស្សរបស់លោក សូមឲ្យលោកបង្ហាត់បង្រៀនបំណេះវិជ្ជា យើងឃើញច្បាស់ថា គ្រូមានអធ្យាស្រ័យរាក់ទាក់ទៅកសិស្ស គេទទួលឲ្យសិស្សសំណាក់អាស្រ័យដោយទឹកចិត្តដ៏រីករាយសប្បាយឥតទើសទាស់អ្វីឡើយ ។ តមកទៀតយើងឃើញថា: ពេលដេក គ្រូតែងរវល់ប្រយ័ត្នមើលសិស្ស ក្រែងលោមិនសប្បាយចិត្ត មិនស្រួលខ្លួន មានជម្ងឺឈឺថ្កាត់ គ្រូតែងពិនិត្យមើលឲ្យ

ដឹងថា សិស្សមកគ្រប់ចំនួន ឬ មិនគ្រប់ចំនួន ជួនកាលសិស្សខ្លះយឺតយូរមិនទាន់មកកាន់ដំណេក គ្រូគង់រង់ចាំសិស្ស មិនហ៊ានចូលទ្វារទេ ព្រោះលោកសិស្សមិនមក ឬ កៀបខ្លួន ទៅដេកឯណាក្រៅពីកន្លែង គ្រូគង់ ឬ អង្គុយចាំបែបនេះមិនថាឆាប់ ឬ យូរទេ ដរាបតាល់តែឃើញសិស្សត្រឡប់ចូលមកកន្លែងគ្រប់ចំនួន ទើបគ្រូចូលកាន់សំណឹងរបស់ខ្លួន ៗ នៅពេលដែលសិស្សធ្វើដំណើរទៅណាមកណា ដោយគ្រូប្រើឲ្យទៅកនេះកនោះ គ្រូតែងគយគន់រំពៃចង្អឹងចាំមើលផ្លូវសិស្ស កាលបើសិស្ស ត្រត្រឡប់មកកន្លែងវិញ គ្រូព្រួយបារម្ភខ្លាច ក្រែងមានគ្រោះថ្នាក់ ឬ មានឧបសគ្គមកកាំងស្កាត់ដំណើរស្កាត់ផ្លូវសិស្ស គ្រូរាប់ដៃកប់ជើង ចាប់យាមរកយលេខអត្ថៈមើលថ្ងៃល្អ ថ្ងៃអាក្រក់ ដោយព្រះអង្គឯង លុះយាមៈទៅឃើញថាល្អ ចំពោះលើទំនាំងល្អ គ្រូក៏ក្សាន្តហឫទ័យបន្តិច បើជួនក្រឡាយាមធ្វើមកថា មិនល្អ គ្រូភ័យបុកពោះ ខ្លាចមានគ្រោះកាចដល់កូនគេ ដរាបដល់ពេលសិស្សត្រឡប់មកវិញ ឃើញច្បាស់នឹងចក្ខុ ទើបគ្រូធូរព្រះទ័យ ត្រេកអរក្រោយធម្មតាដូចដើម ៗ ជួនពេលខ្លះ សិស្សដើរមិនបានឲ្យដំណឹងគ្រូតែងទុកខាងក្នុងចិត្តជានិច្ច ដោយគិតថា មិនដឹងទៅនោះប្រកបដោយសុខៈ ឬទុក្ខ ឬមួយទៅដោយ

មានការអាក់អន់ទឹងចិត្តនឹងអ្នកមិនដឹង ។ គ្រូចាត់ប្រើបំរើឲ្យទៅតាមសិស្សតាំងយប់តាំងអធ្រាត្រ លុះត្រាតែឃើញសិស្សត្រឡប់មកវិញ ទើបសប្បាយចិត្ត ។

ពេលស៊ី = គ្រូដើរពិនិត្យត្រួតមើលជាធម្មតា ក្រែងលោសិស្សខ្លះអត់ សិស្សខ្លះបាន កាលបើឃើញថាសិស្សតាំងអស់នោះ មានម្ហូបចំណីគ្រប់គ្រាន់ហើយ ទើបគ្រូនៅស្ងៀម តែបើសិស្សខ្លះមានម្ហូបចំណីច្រើន ឯសិស្សខ្លះទៀតគ្មាន ដោយខ្លាចគេមិនហ៊ានដណ្តើម ឬចូលរួមជាមួយនឹងគេ គ្រូក៏ចាត់ចែងចែករំលែកចែកឲ្យ ដរាបដល់តែបានស្មើ ៗ គ្នា ។ ឃើញថា គ្រូជាសកាគុណការផងជាអ្នកចែងចំណែកផង ជាអ្នកផ្សះផ្សាសិស្សផង ជាអ្នកផ្សះផ្សាសិស្សដោយទឹកមន្តដ៏ត្រជាក់លើសិស្សតពុទ្ធសាសនាផង ។

ម្យ៉ាងទៀត ក្នុងការថែរក្សាសិស្សនេះ គ្រូត្រូវទទួលមុខងារបំពេញនាទីក្នុងដំណែងជាគ្រូនេះ មានច្រើនក្រសួង ច្រើនដំណែង ប្រសិនណាបើយើងប្រៀបធៀបទៅនឹងក្រសួងផ្សេង ៗ ។ ក្រសួងដែលគ្រូត្រូវបំពេញមានដូចតទៅ :

— ក្រសួងសិក្សាធិការ = គ្រូទទួលអប់រំបង្រៀនហ្វឹកហ្វឺនសិស្សខាងផ្នែកសិក្សាធិការជាតិមានការអប់រំខាងកាយសិក្សា បរិយាសិក្សា

ទិនអប់រំខាងផ្លូវចិត្តជាដើម :

– ក្រសួងយុត្តិធម៌ = គ្រូជាចៅក្រម ឬ សាលយុត្តិធម៌ សម្រាប់ជំនុំជម្រះរកយុត្តិធម៌ឲ្យសិស្សគ្រប់រូប ៗ ដូចជាយើងដឹងស្រាប់ហើយ ធម្មតាសន្តានចិត្តរបស់ក្មេងដែលជាសិស្ស កាលបើមានហេតុ ឬ រឿងអ្វីនឹងគ្នា សូម្បីតែឈ្លោះពាក្យសំដីបន្តិចបន្តួច · ឬក៏បានវត្ថុអ្វី មិនចែកឲ្យគ្រប់គ្នា ក៏រមែងតែងយកជ័យជំនះរៀងខ្លួន ៗ ដោយយករឿងហេតុនោះទៅទូលទៅប្រាប់គ្រូ សូមឲ្យគ្រូកាត់សេចក្តីឲ្យខ្លួនឈ្នះ ៗ នេះជារឿងពិតរបស់សិស្ស ៗ ទោះបីយ៉ាងណាក៏ដោយ គ្រូមិនបានដោយឬក៏ស៊ុយតាមពាក្យញៀកញៀករបស់សិស្សទេ គ្រូតែងសម្រះសម្រួលលួងលោមសិស្ស កាត់ក្តីឲ្យសិស្សទៅតាមសភាពពិត បើអាចធ្វើទៅបាន ៗ បើឃើញថាមិនអាចធ្វើទៅតាមសេចក្តីពិតបាន ដូចជាសិស្សខ្លះខិលខូចហើយចង់បន្ទុចសិស្សឯទៀត ក៏យកលេសណាមួយទៅទូលគ្រូជាដើម គ្រូលួងលោមបបោសអង្អែលថ្នមៗ ឲ្យតែសិស្សប៉ាស្រុះស្រួល កុំឲ្យបែកបាក់គ្នា ឲ្យចេះស្រឡាញ់រាប់អានគ្នាឡើងវិញប៉ុណ្ណោះ ៗ ចំពោះការរកយុត្តិធម៌ឲ្យសិស្សនេះ គ្រូមិនបានជាយកទោសទៅដាក់អំពីផ្ទុំ ដល់សិស្សដែលខិលខូច ប្រព្រឹត្តតាំងនឹងដល់សិស្សដូចគ្នានោះទេ គ្រូគ្រាន់តែស្តីបន្ទោសឬកំហក់ ដោយរំពាត់បន្តិច

បន្តិចប៉ុណ្ណោះ ដើម្បីកុំឲ្យសិស្សដែលជាអ្នកត្រឹមត្រូវស្អប់គ្រូ យកតម្រាប់តាម ទំនងឲ្យសិស្សក្រមាចក្រមើមប៉ុលប៉ូចនោះ ទេះតែប្រព្រឹត្តល្មើសតទៅទៀត ។ ឯចិត្តរបស់គ្រូវិញនៅតែស្រឡាញ់ករុណាសិស្សស្មើៗគ្នាដូចដើម ឥតមានប្រែប្រួល ឬ លំអៀងដោយការស្រឡាញ់ ឬ ស្អប់ទៅលើសិស្សម្នាក់ៗឡើយ ។

– ក្រសួងសុខាភិបាល = គ្រូជាពេទ្យហ្ម សម្រាប់ព្យាបាលជម្ងឺសិស្ស ។ កាលណាសិស្សគ្រូនណាឈឺមិនជាយ៉ាងណាមួយ ដោយជម្ងឺផ្សេងៗ គ្រូអត់ទ្រាំឈឺជាមួយសិស្ស គ្រូព្យាបាលដោយមន្តអាគមស្តោះព្រួសរបស់ខ្លួន បើគ្រូមិនចេះ គ្រូចាត់គេឲ្យទៅរកពេទ្យ ឬ គ្រូស្តោះព្រួសឲ្យជួយព្យាបាលជំនួសលោក, ទោះបើពេទ្យឬគ្រូស្តោះស្ថិតនៅទីឆ្ងាយយ៉ាងណាក៏ដោយ ឲ្យតែដឹងថា ពូកែសក្តិសិទ្ធិ គ្រូចាត់អ្នកបំរើឲ្យទៅយកពេទ្យឬគ្រូស្តោះនោះទាល់តែបាន មិនថាជិត ឬឆ្ងាយឡើយ ។

ក្រៅពីក្រសួង ដូចបានពោលមកខាងលើនេះ នៅមានក្រសួងជាច្រើនទៀតដែលគ្រូត្រូវបំពេញទៅលើសិស្ស ដូចជាក្រសួងមហាផ្ទៃ ការពារប្រទេស ហិរញ្ញវត្ថុ សង្គមកិច្ចនិងធម្មការជាដើម ។ តែក្នុងទីនេះ មិនបានលើកយកមកនិយាយទេ ទុកជាឲ្យអ្នកអានពិចារណា

មើលទៅចុះ ៗ ខ្ញុំគ្រាន់តែបង្រួមសេចក្តីថា ក្នុងការថែរក្សាសិស្ស នេះ គ្រូការពារតាំងពីសិស្សគ្រប់ខ្ទង់គ្រប់ផ្នែកទាំងអស់ ការពារតាំងពីកិត្តិយសសិស្ស រហូតដល់ការពារសេរីគ្រប់បែប ដែលបង្កមកយាយីសិស្ស, មិនឲ្យសិស្សទៀយព្រួយពីរឿងហេតុផ្សេងៗ កាលបើមានហេតុកង្វល់ខ្លែកកើតឡើងចំពោះសិស្ស ដូចជារឿងគេបោងប្រកាន់ដោយមិនសមហេតុផល ថាសិស្សរបស់គ្រូ ជាមនុស្សអាក្រក់ទិលខូច ដើរកេរឿងហេតុគេ ឬ ប្រព្រឹត្តរំលោភទៅលើកូនប្រពន្ធគេជាដើម ៗ គ្រូចេញមុខតក់សម្រុះសម្រួលការពារសិស្ស មិនឲ្យសិស្សកើតទុក្ខ ជាប់ទោសដោយសារតែពាក្យចោទអកុសល ៗ នេះជាពិតតាំងបង្ហាញហ្ឫទ័យរបស់គ្រូ ដែលស្នេហាទៅលើសិស្សគ្រប់រូប មិនយល់មុខថាសិស្សល្អ សិស្សទិលខូចអាក្រក់ឡើយទេ ៗ

ជាពិសេស សិស្សទាំងឡាយដែលលោកគ្រូបានយុំគ្រងគ្រប់មធ្យោបាយហើយ លោកគ្រូក៏នៅពុំអស់ចិត្ត គឺពុំទុកចិត្ត ព្រោះចិត្តគំនិតរបៀបប្រែយនៅទន់ខ្ចីពុំទាន់បាស់ក្លា លោកគ្រូប្រឹងញាក់ស្មារតីសិស្សពីជំនឿឥតសមហេតុផល ពីគំនិតស្អប់គ្រប់ប្រាជ្ញដែលផ្តេកផ្តួលទៅរកព្រេងព័សនា ឬ សំអាងទៅលើកម្មក្រាស់កម្មភាពដែលពុំមានឲ្យប្រផប្រយោជន៍ក្នុងការរស់នៅ, ក្នុងការស្វែងរកអម្រស់របរចិញ្ចឹមជីវិត

ក្នុងការរៀបចំជីវិតតាមហេតុល្អ ៗ មិនបណ្ដោយឲ្យផ្អៀងឲ្យហោលគិត ខិតទៅរកគន្លងខុស ៗ បើតាមចំណាំខ្ញុំអ្នកសរសេរ, ចំពោះទង់ល្អ ៗ ដែលលោកគ្រូបានផ្ដាំ . ចូរអ្នកក្រើនរំលឹកអំពីជីវិត . ព្រេងវាសនា ទីង ១ បាយផ្ទៃព្រេងវាសនាឲ្យកើតកាលវាលគុម្ពចំរុងចំរើនទ្រព្យធន យើងសូមទាញយកមកបញ្ជាក់ថែមទៀតដូចតទៅ :

អ្នកខាង ! ! ព្រេងវាសនា ជារបស់ដែលពពួកសត្វលោកសុំឲ្យបានដោយក្រ ព្រោះអ្វី? ព្រោះការបានកើតមកជាមនុស្សជាការក្របំផុត ; ពុទ្ធភាសិតថា កិច្ឆោ មនុស្សប្បដិលាភោ = ទុល្លភញ្ច មនុស្សត្តំ = ការបានកើតមកជាមនុស្ស ជាការក្រ ក្រដោយអ្វី? ក្រដោយមហាកុសលផលបុណ្យដែលធ្វើច្រើន ៗ កុសលធំធេងណាស់ ទើបអាចបង្កើតជាជីវិតយើងបាន ៗ ព្រេងវាសនា ប្រៀបដូចជានាយជាងវិស្វករដ៏ចំណាន មាតាបិតាប្រៀបដូចជារោងចក្រ ជីវិតមនុស្សលោកប្រៀបដូចជារទេះឡាន ដែលប្រសូតចេញពីរោងចក្រគឺមាតាបិតា ៗ តួចិត្តទាំង ៨៩ ដួង ប្រៀបដូចជាតៃកុងអ្នកបរឡាន (chauffeur) ៗ អ្នកបរឡាននេះ ត្រូវមានចំណេះចេះដឹងច្បាប់ចរ. បរក្នុងប្រទេស ក្រៅប្រទេសដោយល្អិតល្អន់ ជៀសវាងគ្រឿងផុតចំ.

ផ្កាញស្មារតីមានស្រីស្រាដើរលេងជាដើម ដែលជាហេតុបំភាន់ស្មារតី ឲ្យតក់ស្លុតនៅពេលបើកបរថយន្ត ។ បានសេចក្ដីថា ព្រេងកំសាន្ត គ្រាន់តែជួនជំណើរវិបាកវិញ្ញាណរបស់អ្នកនាំងកល់ប្រាណ ឲ្យកើតជាមនុស្សប៉ុណ្ណោះឯង ឯការបើកបរជីវិតត្រង់ផ្លូវ ឬ មិនត្រង់ផ្លូវ ស្រេចនៅលើតែកុងស៊ូហ្វ័រ ( chauffeur ) គឺចិត្តគំនិតបញ្ញាស្មារតីរបស់អ្នកនាំងកល់គ្នា ចុះបើអ្នកកាប់គ្នាជាអ្នកល្ងង់ខ្លៅ មិនព្រមរៀនសូត្រឲ្យចេះដឹង ក៏មិនអាចនឹងនាំជីវិតឲ្យថ្លៃថ្លាបាន ។ ហេតុនេះ អ្នកកល់គ្នាជាតែកុងដ័រ ត្រូវអ្នកកល់គ្នាបម្រុងចិត្តគំនិត សម្រេចជីវិតឲ្យប្រកបទៅដោយហេតុ ៤ យ៉ាង ទើបកិច្ចការផ្សេង ៗ របស់យើងឲ្យផលល្អតាំងពីបច្ចុប្បន្នរហូតដល់អនាគតបាន ។ ចុះហេតុ ឬ សម្បត្តិ ៤ យ៉ាង ដូចម្ដេច ? ហេតុ ៤ យ៉ាងគឺ :

១- គតិសម្បត្តិ: ត្រូវអ្នកកល់គ្នា ប្រឹងរៀនសូត្របំណេះវិជ្ជា អក្សរលេខនព្វន្ធ ឲ្យប្រាកដអាចប្រើការបានមិនទើសទាក់ តាំងនិយាយ តាំងសរសេរតែក្រា ។

២- ឧបធិសម្បត្តិ អ្នកនាំងកល់គ្នា ម្នាក់ៗកាលបើមានបំណេះចេះដឹងជ្រៅជ្រះហើយ ត្រូវខ្វះខ្នះខ្នែង ត្រូវប្រុងប្រយ័ត្នខ្លួនជានិច្ចក្នុងការស្រឡាញ់កេរ្តិ៍ទ្រព្យជាមួយនឹងសង្គមមនុស្ស ហើយចេះឲ្យស្គាល់ខ្លួន បាយ

តាំង៤ (ចូលមើលលេខរៀងត្រង់ទំព័រ២៨ខាងមុខ) ឲ្យប្រាកដក្នុងចិត្ត រៀបចំចរិយាសណ្ដាប់ធ្នាប់ក្នុងការចាយវាយឲ្យល្អ កុំខ្ជះខ្ជាយ កុំលេងស្រីស្រា អាភៀនភ្នាល់បៀ ឬ គប់មិត្តអាក្រក់ ។

៣-កាលសម្បត្តិ យើងបានកើតក្នុងសម័យឯករាជ្យសម្បូរសប្បាយ ។

៤-បយោគសម្បត្តិ អ្នកនោះត្រូវចេះគប់មិត្តល្អជានិច្ច; មិត្តល្អ អាចបង្អុលបង្ហាញៗផ្លូវរកទ្រព្យធនមិនលាក់លៀម ។ របស់អ្វីៗក្នុងលោកដែលថាក្រ ក៏នៅតែគេអាចរកបាន ឯមិត្តល្អកម្ររកបានណាស់ក្នុងលោកនេះ ។ ព្រោះហេតុអ្វី ? ព្រោះជីវិតខ្ញុំក្ដី ជីវិតអ្នកតាំងក្ដី សុទ្ធតែមានការទាក់ទងទៅនឹងវិជ្ជា នឹង គុណ នឹងកាល ហើយនឹងមិត្តភក្តិជាធម្មតា មិនមាននរណារស់តែម្នាក់ឯងបានទេ (បរប្បដិពទ្ធា មេ ជីវិកា) ។ កាលបើយើងមានហេតុទាំង ៤ នេះ គ្រប់គ្រាន់ យើងនឹងបានសម្រេចផលនៃគោលបំណងយើងជាប្រាកដ ។

រៀបរាប់មកនេះ ពុំអស់ដើមពីកិច្ចដែលលោកគ្រូជាកល្យាណមិត្តរបស់សិស្សនៅឡើយ ។ ហេតុនេះ ឧបការៈដ៏ធំធេងដែលលោកគ្រូធ្វើចំពោះសិស្សទាំងមាតាបិតាសិស្សរកអ្វីប្រៀបពុំបាន សូម្បីខ្ញុំសរសេរក៏សរសេរមិនចប់ពីកិច្ចការៈរបស់លោកដែរ ។ នេះ ពិតជាកល្យាណមិត្តរបស់សិស្សពិតប្រាកដមែន ។

# គតិ ទី៣

## គ្រូជាទក្ខិណេយ្យបុគ្គលរបស់សិស្ស

មង្គលត្ថទីបនី

អ្នកដឹងគុណគ្រូ បង្កើតអត្តរូប អ្នកហោងស្មើម្តាយ
ឪឯបានរួបទុក ផុតក្តីអន្តរាយ អ្នកគ្រូស្មើម្តាយ
បង្កើតក្តីច្បាប់ ៗ

បាកកាសិតខុំ ៗ

លោកគ្រូ ក៏ដូចជាមាតាបិតាបង្កើតរបស់បុត្តធីតាដែរ ជាបុគ្គលមានគុណូបការៈគេគួរប្រៀបពុំបាន ៗ ប៉ុន្តែ មាតាបិតាជាបុព្វការីបុគ្គល គឺជាអ្នកមានឧបការៈលើកូនទៅមុនគ្រូអាចារ្យ មានគុណស្មើនឹងព្រះធម៌ ៨៤០០០ ធម្មក្ខន្ធ ដែលព្រះពុទ្ធទ្រង់ត្រាស់សំដែង ៗ លោកគ្រូជាអាចារ្យទី ២ ហៅ ទុតិយាចារ្យ ឬ ទុតិយុបការី អ្នកធ្វើឧបការៈដល់សិស្ស ជាលើកទី ២ បន្ទាប់ពីមាតាបិតាមក ៗ ចំពោះគុណគ្រូយើងពុំអាចថ្លឹងប្រៀបធៀបបានដែរ តែបើតាមច្បាប់ក្រមលោកថែងថា មានគុណធ្ងន់ស្មើម្តាយ ព្រោះគ្រូជាអ្នកបើកផ្លូវសំនៅឲ្យសិស្សដើរ លាងក្អែកដោយទឹកសប់ គឺអក្សរសាស្ត្រ ក្អៀលត្រចៀកស្តារ

អាចមិត្រទៀតដោយកន្លារ គឺ: សុតិ: អប់រំឲ្យចេះស្ដាប់វិជ្ជាការពក់ជ្រៅ លាងចិត្តឲ្យថ្លាស្អាតដោយវិន័យ ព្រោះព្រំដោយទឹកមន្ត គឺព្រហ្មវិហារធម៌ ។ នេះជាគុណធំៗរបស់លោកគ្រូ យើងពុំអាចពិពណ៌នាឲ្យវែងឆ្ងាយបាន តែតិចតួចក្រៅអំពីនេះ សូមត្រិះរិះមើលតាមគតិទី ២ ឯណោះចុះ ។

ហេតុនេះ យើងសូមគូសដៅបញ្ជាក់តែតិច អំពីអត្តរូបរបស់លោកគ្រូចំពោះសិស្សដោយត្រួសត្រាយ តាមដែលយើងធ្លាប់ឃើញធ្លាប់ចាំ ៗ ជីវិតមនុស្សនិងសត្វ មានទិន្នន័យពីធម្មជាតិដូចគ្នា មានការដេក, ស៊ី. ភ័យ និងការបរិភោគកាមដូចគ្នា; មនុស្សនិងសត្វមានមេបាបង្កើតដូចគ្នាក៏ពិតមែន តែមនុស្សដែលប្លែកវិសេសជាងសត្វតិរច្ឆាននោះ គឺមនុស្សមានម៉ែឪបង្កើត មានគ្រូដឹកនាំបង្ហាត់បង្រៀនច្បាប់មនុស្ស បើមនុស្សមានត្រឹមតែម៉ែឪបង្កើត តែពុំមានគ្រូដឹកនាំបើកភ្នែកចេកត្រចៀកប្រមុះទេ ក៏មិនខុសពីតិរច្ឆានដែរ ។ ព្រោះអ្វី? ព្រោះធម្មតាមនុស្សនិកាយ ត្រូវឲ្យមានធម្មសញ្ញា គឺការស្គាល់ខុស-ត្រូវ គុណទោស អាក្រក់ល្អ ទាបខ្ពស់ គួរមិនគួរ ស្គាល់ហេតុ-ផលជ្រៅរាក់ ចេះគ្រប់គ្រងជីវិតដោយច្បាប់របស់មនុស្សដោយជាក់លាក់ ទើបមានតម្លៃខ្ពស់លើសពីភាពសត្វតិរច្ឆាន ។ ខ្ពស់ដោយអ្វី? ខ្ពស់ដោយវិជ្ជា-វិន័យ

របៀបរៀបរយល្អ ចរិយាស្រគត់ស្រគំក្លាហានរឹងប៉ឹង ដោយការរក្សា
នូវកុសលកម្មបថ ១០ មានការមិនបៀតបៀនគ្នា មិនរុកគួនប្រពៃណេន
ទិន្នាមើលងាយគ្នា រំលោភជិះជាន់គ្នាជាដើម ។ ចុះធម្មសញ្ញានោះ
នរណាជាអ្នកឲ្យ? មាតាបិតា - លោកគ្រូ នឹង មិត្រភក្តិកៀនបនល្អ
អប់រំបញ្ចេះបណ្តុះបង្រៀនកែតម្រូវពីខុសទៅកែត្រូវ ពីទោសទៅគុណ
ពីមិនសមរម្យទៅសមរម្យ ពីមិនះយោគយល់គ្នាទៅរកការយោគយល់
គ្នា ពីមិនចេះគោរពគ្នាទៅរកការគោរពគ្នា យកចិត្តថ្លើមគ្នា រកស៊ី
ចែកគ្នា ។ល។ .

ហេតុដូច្នេះ លោកគ្រូពិតជាមាតាបិតាទី២ មានសន្តានចិត្ត
សប្បុរសប្រកបដោយព្រហ្មវិហារធម៌ខ្ពង់ខ្ពស់អនេកអនន្តជាងជនធម្មតា
លោកជាអ្នករៀបចំទោសសំអាតផ្លូវឲ្យសិស្សគណ ជាអ្នកដុះខាត់លើង
ផ្លូវមនុស្ស គឺការអប់រំ ការបង្រៀន ការណែនាំ ការបង្ហាញ។ចាយ
សេដល់សិស្សានុសិស្សប្រកបដោយសម្មាអាជីវៈ ឈមមុខតាម។ចាយដី

ប្រសើរ(១) ។ ម្យ៉ាងទៀត លោកគ្រូមានឧបាយជាច្រើនសម្រាប់ដុសលាងសិស្សគណឲ្យជ្រះផ្អែលមន្ទិលអាក្រក់ ដោយវិធីពេលពត់ខ្លះ អប់រំខ្លះ បង្ហាត់បង្រៀនពន្យល់ខ្លះ បង្ខិតឲ្យរៀនធ្វើខ្លះ ៗ ខាងព្រះពុទ្ធសាសនាលោកបំបួសជាសាមណេរ ជាភិក្ខុ ការនាំអប់រំបង្ខំនិស្ស័យសិស្សដោយល្បិចឯទៀតជាច្រើនខ្លះ មានការពិភាក្សាធម៌អាថ៌សាស្ត្របាលីជាដើម ។

ខាងសង្គមធម៌ , លោកគ្រូដឹកនាំឲ្យចេះគោរពមាតាបិតា គោរពគ្រូរៀមច្បង ឲ្យចេះនិយាយពាក្យទន់ភ្លន់ផ្អែមល្ហែម ឲ្យរៀននិយាយតែពាក្យណាសមរម្យមានល័ក្ខគោលតម្រង់ខាងត្រឹមត្រូវ ឲ្យរៀនលះបង់សេចក្តីកំណាញ់លោភ កំណាញ់ឫកពា ឲ្យនិយាយតែពាក្យពិត ឲ្យចេះរៀនអត់ធ្មត់គ្រប់សង្កត់ទោសៈ ខឹង ក្រោធជាដើម ។ ចុះមានអ្វីក្រៅពីនេះទៀត ដែលលោកគ្រូអភិរក្សថែសិស្សឲ្យល្អ ?

---

(១) ឧបាយរស់នៅ បានសុខចំរើនគ្រប់វិស័យ មាន ៤ យ៉ាងគឺៈ ១— សាមញ្ញឧបាយៈ ស្គាល់កិច្ចការរៀបចំស្រុកស្គាល់ច្បាប់សេដ្ឋកិច្ចជាដើម, ២— តក្កឧបាយៈ ឈ្លាសវៃក្នុងវិធីបង្កើតទ្រព្យនឹងវិធីជំនួញជួញប្រែជាដើម, ៣— លេហុបាយៈ ស្គាល់ល្បិចដោះស្រាយជីវភាពខ្លួនទៅនៃរាជការមិនល្បិចកលពាលទុច្ចរិត, ៤— ធនុបាយៈ ស្គាល់ឧបាយ ឬវិធីបង្កើតទ្រព្យដោយប្រកល្បិចកលផ្សេងៗ មិនរើសខាត់គំនិត ។ ពុទ្ធភាសិតថា អនុបាយេន យោ អត្ថំ ឥច្ឆតិ សោ វិហញ្ញតិ នរណាស្វែងរកប្រយោជន៍គ្មានឧបាយ នរនោះលំបាកពោកយ៉ាក ។

សរុបហេតុទៅ , លោកគ្រូជាបុគ្គលធ្វើការកម្រ ដែលអ្នកផងពិបាក
នឹងធ្វើបាន ព្រោះបុរាណបណ្ឌិតពោលថា « ក្រកិច្ចក្រកល ក្រដឹង
ក្រយល់ ក្រចិត្តធានា ក្រវៃឆ្លាស់ ធ្វើយផ្លាស់លោកា ក្របានជាបា
រមីគេតាំងឡាយ » ។ ឃើញថា លោកគ្រូមិនមែនត្រឹមធ្វើខ្លួនឲ្យបាន
ទៅជាមនុស្សល្អរបស់សង្គមទេ គឺលោកគ្រូសិក្សាធម៌មិកាថ ក្បួនច្បាប់
គម្ពីរបាលីបេះតាំងគ្រប់គ្រាន់ហើយ, រៀនបដិបត្តិហាត់ពត់ចិត្តគំនិតខ្លួន
ឲ្យទៅជាមនុស្សពេញរស់នៅល្អ ជាមនុស្សបានហើយ, រៀនគរុកោ-
សល្យ•នាយកធម៌•សង្គមសាស្ត្របេះដឹងហើយ លោកគ្រូរៀនហ្វឹក
ហ្វឺនខ្លួនឲ្យទៅជាមិត្តរបស់មនុស្ស មារយាទថោកទេ មារយាទថ្លៃ
ថ្លាវៃសយក, ហាត់ពត់កាយឲ្យសុភាពរាបសាក្នុងការប្រាស្រ័យទីង
មហាជន ហាត់ពត់សំដីថ្មីមាត់ក្នុងការបេវាកុំទាក់ទងរកមិត្តភក្តិទីង
ញាតិសន្តានជិតឆ្ងាយ, រៀនពត់ចិត្តឲ្យជាអ្នកបេះអត់ធ្មត់ច្រើន,
បេះយោគយល់ច្រើន, លះបង់អគតិធម៌, ។ មន្តរៀនអាគមគាថា
ផ្សេងៗទៀត ក៏លោកគ្រូមិនទៅចំនេរ, លោកគ្រូធ្វើជាគ្រូពេទ្យ
របស់សិស្សគណ, ជាហោរបស់សិស្ស ។ សិស្សទាំងអស់ លោក
គ្រូដឹកនាំដោយវិធីសាស្ត្រជាច្រើន សិស្សណាដែលបំពេនខ្ជិល លោក
វាយពត់ខ្លះ ណាក្មេងបានឈ្នានពាន កំដាក់ទណ្ឌកម្មខ្លះ ស្រាលខ្លះ

ណាបែបកៀកក្រាញ ត្រូវបញ្ឈរ កំផ្លោរ ល្មមរាយក៏រាយដែរ ដោយពាក្យផ្អែមខ្លះ ណាបែបគួរសម ឬ រៃផ្ចាកក៏លោកលើកកេរ្តិ៍ឈ្មោះ កិត្តិគុណ, ប្រកាសប្រាប់អ្នកផងជាទាយក-យិកា ឧបាសក-សិកា នៃសិស្សទាំងអស់ លោកគ្រូហៅមកសួរថ្ងៃ ខែ ឆ្នាំ កយដើម លេខ អត្ត: គន់គូរមើលក៏ឮព្រេងវាសនា ជោគជតាកសិ ហេតុផល គ្រួសារ ក៏មាន ។ កិច្ចដែលបរិយាយមកនេះ ជាឧបាយរាយគោះ សិស្សឲ្យបែរឆ្ពោះទៅរកផ្លូវត្រូវ-សុខ ចំរើនតាមកម្លាំងវិរិយភាព មិន ព្រេងវាសនាសិស្ស ។ លោកមិនបណ្តែតបណ្តោយសិស្សឲ្យទៅឆ្ងាយ ពីខ្លួន ពីកុដិដែលលោកនៅទេ ។ កិច្ចទាំងនេះជាកិច្ចកម្ម ដែលលោក គ្រូជំនាន់កាលណានិគមប្រឹងប្រែងធ្វើមិនខ្លាចនឿយហត់ . ព្រោះចង់ ឲ្យសិស្សល្អ ចង់ឲ្យសិស្សមានគុណឧត្តុង្គឧត្តម ចង់បានស្មើប្រសើរ, គឺសិស្សគណពលរយនាក់ដែលលោកគ្រូអប់រំនេះឯង, ជាពិសេស គឺ លោកគ្រូមិនគ្រាន់តែជាគ្រូរបស់សិស្សទេ គឺជាមហាកល្យាណមិត្រដ៏ បណ្តាប់ជាមួយដ៏គ្រជាក់ជាអគ្គមគ្គុទ្ទេសក៍ ជាពេទ្យហ្ម ជាគ្រូ ជាស្ពាន ឆ្លងទៅរកទីត្រូវ ទីសុខ-ចំរើនគ្រប់ប្រការ ជាគោលនៃសិរីសួស្តីជ័យ មង្គលជោគជតាកសិរបស់សិស្សទាំងពួង ។

ពន្លឺព្រះគាថាក្តី ពន្លឺប្រទីបបាន្ទៀនគោមក្តី ដែលអ្នកផងពោល

ជាក្តី  ក៏មានពន្លឺតែមួយចំណែកគ្រាន់តែកំចាត់បង់ភាពងងឹតធម្មតានៃរាត្រីកាលប៉ុណ្ណោះ  ឯពន្លឺគឺសតិបញ្ញាចក្ខុដែលលោកគ្រូបង្កើតឲ្យមានដល់សិស្ស ក្តីជាងពន្លឺព្រះអាទិត្យនិងពន្លឺចង្កៀង ព្រោះពន្លឺនោះ ទោះបីហេតុការស្មុគ្រស្មាញល្អិតល្អន់ងងឹតយ៉ាងណា  ក៏អាចជ្រែកស្នៀតទី គឺបញ្ញានោះ  ចូលទៅកាត់ក្តីសោកមោហនោះៗបានគ្រប់ពេលវេលា មិនបាច់អុចប្រទីបកវែកជងបានដោយច្បាស់លាស់ ។

មិត្រភក្តិ ឬ កៀនបទរបស់សិស្ស  ដែលមានចិត្តថ្លើមស្មើគ្នាមានគតិដូចគ្នា មានបំណះប៉ុនគ្នា  មានគោត្រកូល-ទ្រព្យសម្បត្តិដូចគ្នា ក៏ពុំស្មើនឹងមិត្តគឺគ្រូបាអាចារ្យនេះដែរ  ព្រោះលោកគ្រូមិនមានទឹកបាំងទៅលើសិស្ស, ឃើញខុសប្រាប់ថាខុស  ឃើញត្រូវប្រាប់ថាត្រូវ មិនលាក់លៀម, ឃើញល្អដឹកនាំឲ្យចេះជឹង  ឃើញទោសផ្តាំផ្ទួន រំលាងសិស្សឲ្យល្អសមរម្យស្គួតបូតត្រឹមត្រូវ  ជាមនុស្សប្រសើរ ។ល។

ម្លប់ឈើព្រៃនិងអាំងពូក មានគតិគួរដល់ការជ្រកកោនដល់មនុស្សឥតរើសមុខ ឥតរើសពណ៌សម្បុរ  អាក្រក់ល្អស ខ្មៅក៏ពិតមែនតែម្លប់គឺគ្រូបាអាចារ្យនេះ មានទឹកដមមានរសជាតិ  មានក្លិនក្រអូបឈ្ងុយឈ្ងប់មានខ្យល់ផាំនោរបក់ផ្សព្វផ្សាយគឺព្រហ្មវិហារធម៌ទៅលើសិស្សគណ គ្មាននរណាប្រៀបបាន ។  ទោះបីអ្នកជ្រកកោន គឺសិស្ស មានចំនួនច្រើន

មានចិត្តខុសគ្នា មានត្រកូលខុសគ្នា ក៏ដោយក៏គ្រូ នៅតែមានផ្លូវឲ្យសិស្ស ដើរកោនបានដូចបំណងចិនប្រាថ្នា ។ ម្យ៉ាងទៀត មានឥទ្ធិពលត្រឹម តែញ៉ាំងអ្នកដើរឲ្យរួចខ្លួនចាកក្តីកង្វល់ គឺការក្តៅ និងកំដៅព្រះអាទិត្យ ឬ បំបាំងទឹកសន្សើមមិនឲ្យធ្លាក់ទៅត្រូវប៉ុណ្ណោះ ឯម្លប់គឺ គ្រូនេះមាន បុណ្យជាម្លប់ការពារ , មានសីលជាមែកធាងសន្ធឹងត្របពីលើ , មាន មេត្តាជាទឹកជមសំរាប់ស្រោចព្រំ , មានសច្ចៈជាស្លឹកសំរាប់ការពារសែង កំដៅ មានអាហារភោជនដែលទាយក-យិកា , ឧបាសក-សិកាគេបូជា ជាស្បៀងសំរាប់ឲ្យអ្នកដើរគឺសិស្សគណសោយ , មានវិជ្ជាជាឱសថ ការពារជម្ងឺគឺ ភាពល្ងង់ខ្លៅ , មានខន្តីជាទឹកមន្តសំរាប់ផឹក , មានគុណូប ការៈជាគ្រែទំនេនសយនាក្រឡាបន្ទុំសំរាប់សិស្ស , មានទឹកសម្រាប់ លុបមុខគឺការដាស់តឿនក្រើនរំលឹកដេរពេលរ៉ាយប្រដៅ សំរាប់លុប មុខក្រោយពេលក្រោកពីដេក , មានវិន័យជាច្រាស ( ឈើស្ទន់ ) សំរាប់លាងមន្ទិលចេញ គឺបរិយាកាសក្រក់ចោលចេញ ។ល។

កិច្ចកម្មដែលលោកគ្រូធ្វើនេះ មានភារៈខ្ពស់ជាពីជាបលើសលប់ ស្មើមាតាបិតា ( គ្រូសម័យអាណានិគម ) រាប់បានថាជាឧត្តមកម្មមួយ ដែលពួកមនុស្សពិបាកធ្វើឲ្យដូចបាន ។ ហេតុនោះ ជនជាសិស្ស បន្ទាត់ក្តី ជាសិស្សបំបួសជាសាមណេរក្តី ជាសិស្សបំបួសពាំងពីរ

ផ្ទាល់ក្ដី ឬជាសិស្សគ្រាន់តែបានទទួលឱវាទពីលោកក្ដី ត្រូវតែចាត់ការគោរពបូជាតបស្នងសងគុណគ្រូដែលបានធ្វើកិច្ចអាចារ្យ គឺការបណ្ដុះបណ្ដាលឲ្យចេះដឹងជ្រៅជ្រះស្គាល់គុណ-ទោស ឲ្យបានគ្រប់ពេលវេលាដោយសក្ការៈក្ដី ដោយការប្រតិបត្តិតាមឱវាទក្ដី គឺតាមតែអាចធ្វើបាន ។ អ្នកមិនគោរពបូជាគ្រូ ឈ្មោះថារមិលគុណ ទ្រុស្តគុណ ទាំងឈ្មោះថាជាអ្នកស្ថិតនៅក្នុងមាត់នៃមច្ចុរាជពិតប្រាកដ ។ ព្រោះគ្រូជាទក្ខិណេយ្យបុគ្គល គឺជាបុគ្គលគួរដល់ការក្រាបសំពះគោរពបូជាតបស្នងសងគុណដោយសក្ការៈពីសិស្ស គួរតែសិស្សគ្រប់រូបកុំបីប្រមាថមើលងាយដោយចិត្តអាក្រក់នៅពេលណាមួយសោះឡើយ ៕

មានពាក្យបរម្បរាថា: គ្រូសព្វថ្ងៃនឹងគ្រូជំនាន់មុន មានគតិខុសគ្នា ព្រោះគ្រូជំនាន់មុនធ្វើការកម្រចំពោះសិស្ស ហើយគ្មានផលចាត់ម៉ឺទេ ឯគ្រូសព្វថ្ងៃគ្មានគុណទេ គឺទុកដូចជាមិត្រធម្មតាទៅវិញ ។ បើតាមសណ្ដាប់ចំពោះដំណើងចង្រៃនេះ យើងមានចិត្តសោមនស្សផង អាណិតអាសូរចំពោះអ្នកពោលផង ។ ទំនងជាសន្និដ្ឋាន « ពាក្យគុណនេះ ធ្ងន់លើសភ្នំកំភឹសអស់ » ដូច្នេះក៏មិនដឹង? ឬក៏គុណនោះមានចំណែកត្រង់គ្មានស៊ីឈ្នួលស៊ីប្រាក់ខែក៏មិនដឹង? អ្នកពោលនោះទំនងជាចូលចិត្តថា ; គ្រូជាបុគ្គលមានតេជៈសក្តិសិទ្ធិហោងណាចំពោះ

ខ្លួន ទើបគួរតែថាគ្រូមានគុណវិមនទៅវិញ? តើពាក្យថា «គុណ» នេះ មានជម្រៅប៉ុនណា ដែលអ្នកផងយកទៅវាយថ្លៃគ្រូ ឬ មាតាបិតា?

បើតាមយើងដែលបានចុះស្នាម ការសិក្សាស្រាវជ្រាវពិនិត្យមតិទាំង ៣ ផ្នែក គឺមតិពួកតក្កវិទ្យា, មតិពួកវិទ្យាសាស្ត្រ និង មតិព្រះពុទ្ធសាសនា ។ មតិទាំង ៣ នេះ មតិដែលចុះសម្រុងគ្នាដោយហេតុ-ផល គឺមតិអ្នកវិទ្យាសាស្ត្រ និង មតិព្រះពុទ្ធសាសនា ។ តែមតិអ្នកវិទ្យាសាស្ត្រ បដិសេធថាមាតាបិតាក្តីគ្រូអាចារ្យក្តីគ្មានគុណទេ តែទីឯទៀតនិយាយមានហេតុ-ផលល្អដូចព្រះពុទ្ធសាសនាដែរ ។ ចុះហេតុអ្វី ទើបព្រះបរមគ្រូវាយតម្លៃនៃការចិញ្ចឹមថែរក្សាកូនប្រុសស្រីថា មានគុណប្រមាណមិនបានទៅវិញ ចំពោះការតបគុណត្រឡប់ទៅយកព្រះធម្មក្ខន្ធ ៨៤០០០ ថាមានតម្លៃប្រៀបបាន ?

តាមគម្ពីរវេយ្យាករណ៍ ពាក្យថា « គុណ ឬ គុណសព្ទ » នេះ ប្រែថា « លើស, ច្រើនជាងចំណែកធម្មតា, ចំរើនកើនទ្វេជាពីរ ជាបីឡើងទៅ » ហៅថា « គុណ » ។ មនុស្ស: នេះ ជាឈ្មោះធម្មតា មានភាពដូចជាមនុស្សឯទៀត តែបើមនុស្សណាមួយ មានការចេះដឹងច្រើន មានការដឹកនាំញុំអ្នកផងឲ្យចេះដឹងតាម ហើយខ្លួនឯងក៏មានការប្រតិបត្តិគតិវិធីត្រឹមត្រូវ ប្រកបដោយមេត្តា ស្មោះត្រង់

ទៅលើមនុស្សទូទៅ ៗ មនុស្សនេះ ចំរើនចំរៀកជាធម្មតា, តាម ពាក្យហៅគេ គេហៅថា មនុស្សល្អ-ប្រសើរ-អស្ចារ្យ-ខ្ពង់ខ្ពស់ដោយ រូបរួមថា: មនុស្សមានគុណតាប់ប្រសើរ មានសីលគុណជាដើម ។

កូនរបស់ម៉ែឪ តាំងពីបឋមបដិសន្ធិ ប្រសូតជីវិតរហូតដល់ធំ ពេញកម្លោះក្រមុំ មានការចំរើនដោយវ័យ ហៅវ័យវុឌ្ឍិ ឬ វ័យគុណ មាតាបិតា បានធ្វើកិច្ចចំរើនទៅលើជីវិតកូនតាំងពីការខំប្រឹងថែរក្សាគភ៌ រហូតដល់កូនប្រសូត, កាលណាកូនចេញពីពោះម្ដាយហើយ ម្ដាយ លះបង់កាយក្រមុំកម្លោះពេលអស់ ទំថែរក្សា-បីបាច់-ថ្នាក់ថ្នមបំពីមកូន កាលម៉ែប្រសូតបុត្រម៉ែអាំងភ្លើង ( ម៉ែជំនាន់សំណាក់និគមស្រុកស្រែ ) ផឹកថ្នាំក្រាំដោយស្រា ឬ ដោយទឹកមូត្រ ថ្នាំណាគេថាល្អកែ ម៉ែប្រឹង ធ្វេចលេបទាំងអស់ ដើម្បីឲ្យបានឃើញមុខកូន បានសុខមាន សំណាង ដើម្បីចិញ្ចឹមកូន, អត់ភ្លើងផង បណ្ដៅកូនផង បំណាំណាមិន គួរ ម៉ែមិនហានទទួលទានព្រោះតែជីវិតកូន, កូនយំម៉ែលួងម៉ែព្រៀង ពន្យះនាយអាយផ្ទះម៉ែបំបៅតកូនម៉ែបាត់យំ, កូនជុះ-នោម ម៉ែយកដៃ ធ្វើជាកន្ទោរត្រងលាមកកូន, ម៉ែយកដៃកាន់លាមកកូនដូចជាម៉ែឃើញ មាស ឬ ពេជ្រ ។ កូនគេងម៉ែបួបំពេរ ពីដើមកាលនៅក្រមុំម៉ែ មិនចេះបំពេរ ដល់ធ្វើជាម៉ែរបស់កូនហើយម៉ែចេះទាំងអស់ ធ្វើយ៉ាង

ណាឲ្យតែកូនម៉ែដេកសុខស្រួល, ជួនកាលម៉ែយកខ្លួនជាសត្រូវនឹងបាណកសត្វ រុយ-មូស-សុចជាដើម ម៉ែធ្វើបាណាតិបាតចំពោះសត្វនោះ ការពារកូនកុំឲ្យសត្វនោះឃាំយីកូនម៉ែ ។ ម៉ែបង្រៀនកូនតាំងពីកូនបេះលើកដៃលើកជើង ដោយហៅខ្លួនឯងធ្វើយខ្លួនឯង ។ល។ ម៉ែខំទុកបំរុងកូនដោយព្រហ្មវិហារធម៌ ឥតមោះមៃចំពោះកូនហូតដល់រៀបចំគូស្រករឲ្យ ទើបម៉ែស្រាកនឹកគិតកូន ។ នេះ ហៅថាគុណ- គឺចំនួននៃសេចក្ដីចំរើនច្រើនលើសលប់ទៅលើកូន គឺធ្វើអ្វីឲ្យតែដើម្បីកូនម៉ែ ហើយម៉ែប្រឹងធ្វើរស់ពីពោះពីពុងឲ្យតែកូនម៉ែបានល្អ ។ ការត្រូសត្រាយគូសវាសមកចុំណេះ គឺដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ចំពោះពាក្យថាគុណមួយមាត់ ។

ចំណែកគ្រូវិញ ដែលទំនប់របណ្ដុះបណ្ដាលសិស្ស តាំងពីនមោ, ក.ខ. រហូតដល់សិស្សបេះជើងត្រឡប់ក្រឡាយនោះ សេចក្ដីចំរើនគ្រប់វិស័យនៃសតិបញ្ញាចរិយា. សុជីវធម៌. សីលធម៌ , សន្តិមធម៌ ឬ កាព្យធម៌. អក្សរសាស្ត្រជាដើម ក៏សិស្សបានទទួលពីលោកគ្រូទាំងអស់ សេចក្ដីចំរើនចំពោះសិស្សថែបនេះឯង លោកហៅថាគុណ ពោះបើគ្រូជំនាន់មុនក៏ចប់រោគអាហារដូចសិស្ស អាហារមានមកពីលុយ លុយមានមកពីគុណ គឺវិជ្ជាការរបះជើងរបស់គ្រូ ។ គ្រូធ្វើការដោយ

ថ្ងៃឈ្នួល ក៏ដូចជាគ្រូធ្វើការឥតថ្លៃថ្នូរដែរ ។ ដោយហេតុនោះ សូម្បី មិត្រកល្យាណ ក៏មានគុណប្រសើរចំពោះគ្នានឹងគ្នាដែរ លោកឲ្យគោរព គ្នាទៅវិញទៅមក ។

ហេតុនេះ គ្រូក្តី មាតាបិតាក្តី ពិតជាមានគុណរកថ្លៃមិនបាន ទៅលើសិស្សគណកូនចៅ ។ ដើម្បីឲ្យបាននូវសេចក្តីសុខក្សេមក្សាន្ត សិស្សត្រូវគោរពគ្រូ កូនត្រូវគោរពមាតាបិតា បើមិនគោរពបូជានោះ កាពតិរច្ឆានទទឹងលោកទុំលើអំបែងក្បាលប្រាកដ គួយ៉ាងនឹងក្តៅធ្វើមមុន ឥតុយោគយល់ម៉ែឪជាដើម ។

តាមសេចក្តីក្នុងគម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត . បុគ្គលដែល គួរគោរពបូជា មិនត្រូវនរណាប្រមាថមើលងាយនោះមាន ១០ ពួក ដើម្បីឲ្យស្រួលដល់ការចេះចាំផង យើងសូមដកស្រង់ពាក្យបាលីគាថា បកប្រែក្នុងទីនេះ ។

ពុទ្ធោ បច្ចេកពុទ្ធោ ច អរហា អគ្គសាវកោ
មាតាបិតា គរុ សត្ថា ញាយកោ ធម្មទេសកោ
បណ្ឌិតេហិ ឥមេ ទស ឆ· ទុព្ពត្តិ ជាតិយា

ព្រះពុទ្ធ១, ព្រះបច្ចេកពុទ្ធ១, ពួកព្រះអរហន្ត១, អគ្គសាវក១,

មាតាឯ, បិតាឯ, គ្រូឯ, សាស្ត្រាចារ្យឯ, ពាក្យគំអកផ្តល់អាមិស ទៀតឯ, អ្នកសំដែងធម៌ឯ; បណ្ឌិតគួរជ្រាបថា បុគ្គលទាំង ១០ ពួកនេះ គឺនរណាមួយប្រទូស្តមុនបាន ។

តាមហេតុដែលពោលមកនេះ គ្រូជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរបំផុតរបស់សិស្សពិតប្រាកដ មិនមែនគ្រាន់តែជាម្ចាស់សម្រាប់ជ្រែកម្តងម្កាលនោះទេ ។ គួរតែសិស្សកាល់រូបគោរព បូជា ប្រណិបតន៍ដោយ កាយ វាចា ចិត្តដ៏ស្មោះត្រង់ កុំប្រមាថមើលងាយ កុំប្រមាណតាមតក្កហេតុដែលខ្លួនត្រិះរិះ ប្រាសចាកហេតុផលនោះជាការមើលគុណទាំងស្រុង យូរៗទៅ សង្គមមនុស្សនឹងក្លាយទៅជា អនាធិបតេយ្យ ( Anarchie ) ព្រោះតែការប្រើអំណាចចំណង់ចិត្ត (សិទ្ធិសេរីភាព) ហួសហេតុប្រាសចាកន័យមនុស្ស ។

### សុភាសិតមេត្តធម៌

អ្នកដែលធ្វេសប្រហែសគ្រូខ្លួន ឈ្មោះថាល្ងង់ព្រោះគាបមួយ
យ៉ាងណា ដូចផ្កាដែលគេកាយត្រូវមួយជំពូក យ៉ាងដំណាំដែរ !!